មកដម្កល់ទុកកន្លែងដ៏សមគួរ ត្រូវប្រគេនគ្រឿងលំអិតសម្រាប់ដុត ត្រូវប្រគេនដីស្អិតផង បើសន្ធិវិហារិកអាច ត្រូវចូលទៅកាន់ពោធិក្លែង កាលចូលទៅកាន់ពោធិក្លែងត្រូវលាបមុខដោយដីស្អិត ហើយបិទបាំង(កាយ)អំពីខាងមុខផង អំពីខាងក្រោយផង ហើយចូលទៅកាន់ពោធិក្លែងចុះ សន្ធិវិហារិកមិនគប្បីអង្គុយជ្រៀតជ្រៀតកកុមាំងឡាយជាថេរៈ មិនគប្បីហាមឃាត់កកុមាំងឡាយដោយអាសនៈឡើយ ត្រូវធ្វើបរិកម្ម(គឺកិច្ចមាំងពួងមានឲ្យនូវដីល្អិតនិងទឹកក្តៅជាដើម) ដល់ឧបដ្ឋាយ៍ក្នុងពោធិក្លែង កាលចេញអំពីពោធិក្លែង ត្រូវនាំយកតាំងសម្រាប់ពោធិក្លែងហើយបិទបាំង(កាយ)អំពីខាងមុខផង អំពីខាងក្រោយផង ហើយសឹមចេញអំពីពោធិក្លែងចុះ ត្រូវធ្វើបរិកម្មដល់ឧបដ្ឋាយ៍ក្នុងទឹកផង បើសន្ធិវិហារិកងូតទឹករួចហើយ ត្រូវឡើងមុនឧបដ្ឋាយ៍ ហើយជូតកាយរបស់ខ្លួនឲ្យស្ងួតទឹករួចសឹមស្ងៀកហើយទើបជូតទឹកអំពីកាយរបស់ឧបដ្ឋាយ៍ ត្រូវប្រគេនសម្ពត់ស្ងៀកប្រគេនសង្ឃាដិ ហើយត្រូវកាន់យកតាំងសម្រាប់ពោធិក្លែងមកជាមុន ហើយត្រូវលាអាសនៈរៀបចំទឹកសម្រាប់លាងដើង តាំងសម្រាប់វេដើង ក្បឿងសម្រាប់ជូតដើង ត្រូវសួរឧបដ្ឋាយ៍អំពីទឹកនាន់ៗ បើសន្ធិវិហារិកមានសេចក្តីប្រាថ្នាដើម្បីរៀនបាលី គប្បីរៀនបាឡីចុះ បើមានសេចក្តីប្រាថ្នាដើម្បីរៀនអដ្ឋកថា គប្បីរៀនអដ្ឋកថាចុះ ។ ឧបដ្ឋាយ៍

វិហារតំ សចេ សោ វិហារោ ទុក្ខាចោ ហោតិ សចេ ឧស្សហតិ សោឧត្តរេឡ្ហ វិហារំ សោធេត្តព្ពេ បឋមំ បត្តចីវរំ ឧបហរិត្វា ឯកមន្តំ និក្ខិបិតព្ពំ និសីទនបច្ចត្ថ-រណំ ឧបហរិត្វា ឯកមន្តំ និក្ខិបិតព្ពំ កិសិតិម្ពោហនំ ឧបហរិត្វា ឯកមន្តំ និក្ខិបិតព្ពំ បញ្ចោ ឧច្ចំ កត្វា សា-ធុកំ អបរិឃំសន្តេន អសង្ឃដ្ដន្តេន ភាជនបិដ្ឋំ ឧបហ-រិត្វា ឯកមន្តំ និក្ខិបិតព្ពោ បឋមំ ឧច្ចំ កត្វា សាធុកំ អបរិឃំសន្តេន អសង្ឃដ្ដន្តេន ភាជនបិដ្ឋំ ឧបហរិត្វា ឯក-មន្តំ និក្ខិបិតព្ពំ មញ្ចបដិបាទកា ឧបហរិត្វា ឯកមន្តំ និក្ខិបិតព្ពា ខេឡមល្លកោ ឧបហរិត្វា ឯកមន្តំ និក្ខិប-តព្ពោ អបស្សេនផលកំ ឧបហរិត្វា ឯកមន្តំ និក្ខិបិតព្ពំ កុម្ភត្ថវណំ យថាបញ្ញត្តំ សល្លក្ខេត្វា ឧបហរិត្វា ឯកមន្តំ និក្ខិបិតព្ពំ សចេ វិហារេ សន្ថានកំ ហោតិ ឧល្លោកា បឋមំ ឧបហរេតព្ពំ អាលោកសន្ធិកណ្ណកតា បមដ្ឋិតព្ពា សចេ តេរុកបរិកម្មកតា កិត្តិ កណ្ណកិតា ហោតិ ចោ-ឡកំ តេមេត្វា បីឡេត្វា បមដ្ឋិតព្ពា សចេ តាឡវណ្ដ-

នៅកន្លែងវិហារណា បើវិហារនោះមានសម្រាម បើសទ្ធិវិហារិកអាចធ្លើបាន វិហារនោះសទ្ធិវិហារិកត្រូវដម្រះសំអាត កាលដែលដម្រះសំអាតវិហារ ត្រូវយកជាតិនឹងចីវរទៅដម្កល់ទុកកន្លែងដ៏សមគួរជាមុនសិន ត្រូវនាំយកកម្រាលអង្គុយទៅដម្កល់ទុកកន្លែងដ៏សមគួរ ត្រូវនាំយកពូកនឹងខ្នើយទៅដម្កល់ទុកកន្លែងដ៏សមគួរ សទ្ធិវិហារិកដែលនឹងនាំគ្រែចេញ ត្រូវធ្វើឲ្យតាបស្រួលកុំឲ្យទង្គិចទង្គិចកនឹងផែនដី កុំឲ្យប៉ះសន្ទះទ្វារនឹងក្របទ្វារហើយនាំយកទៅដម្កល់ទុកកន្លែងដ៏សមគួរ សទ្ធិវិហារិកដែលនឹងនាំតាំងចេញ ត្រូវធ្វើឲ្យតាបស្រួលកុំឲ្យទង្គិចទង្គិកផែនដី កុំឲ្យប៉ះសន្ទះទ្វារនឹងក្របទ្វារហើយនាំយកទៅដម្កល់ទុកកន្លែងដ៏សមគួរ សទ្ធិវិហារិកត្រូវនាំយកទែនាប់គ្រែទៅដម្កល់ទុកកន្លែងដ៏សមគួរ សទ្ធិវិហារិកត្រូវនាំកន្ទោរទៅដម្កល់ទុកកន្លែងដ៏សមគួរ សទ្ធិវិហារិកត្រូវនាំយកផែនក្តារសម្រាប់ផ្អែកទៅដម្កល់ទុកកន្លែងដ៏សមគួរ ត្រូវបំណាំឲ្យច្បាស់នូវគ្រឿងកម្រាលផែនដីដែលគេគ្រលាំងណាហើយនាំទៅដម្កល់ទុកកន្លែងដ៏សមគួរ បើគ្រឿងស្មុកស្មាញ (សម្រាមមានសំបុកកន្ធាតនឹងសរសៃពីងពាងជាដើម) មានកន្លែងវិហារ សទ្ធិវិហារិកត្រូវបោសតាំងអំពីពិតានជាមុន កន្ទុតជ្រុងសន្ទះបង្អួច សទ្ធិវិហារិកត្រូវដូតសំអាត បើជញ្ជាំងដែលគេលាបដោយរ៉ែមានសៅហ្មងពណិសម្បុរ ត្រូវជ្រលក់សម្ពត់ហើយពូតរួចសឹមដូត បើផ្ទៃដែលគេលាបដោយពណ៌ខ្មៅ

ตตฺถ ภูมิ ตณฺฑุลาทิตา เวทิตพฺพา ปิโยปฺย-
ตฺถา ปมชฺชิตพฺพา สเจ อตตฺถา เวทิตา ภูมิ ๆ ธนเจน ป-
ริจฺจาเสตฺวา สมฺปชฺชิตพฺพา ยา วิหาเร วเสน ๆปาทิยิตฺ
สงฺการาทิวิธินา ปจฺจุปฏฺฐาตพฺพา กุฏฺฐตฺถาณา ปิตาเปตฺวา
สาเธตฺวา ปเปฺปาเสตฺวา[๑] อติหาเรตฺวา ยถาปญฺญตฺตํ ปญฺ-
เปตพฺพา มญฺเปฺปฏิฐาเนน ปิตาเปตฺวา ปมชฺชิตฺวา อติหาเรตฺวา
ยถาฐาเน ปเปตพฺพา ยาวุ ปิตาเปตฺวา สาเธตฺวา
ปเปฺปาเสตฺวา[๒] ลิขิตฺวา ตตฺถ สาธุกํ อปริโยสาเนน อ-
สชฺฌายนฺเตน ตกฺกาทิปิฏฺฐ อติหาเรตฺวา ยถาปญฺญตฺตํ ปญฺ-
เปตพฺพา ปิปิ ปิตาเปตฺวา สาเธตฺวา ปเปฺปาเสตฺวา[๓]
ลิขิตฺวา ตตฺถ สาธุกํ อปริโยสาเนน อสชฺฌายนฺเตน
ตกฺกาทิปิฏฺฐ อติหาเรตฺวา ยถาปญฺญตฺตํ ปญฺเปตพฺพา กิสิ-
พาณิชฺชาทิ ปิตาเปตฺวา สาเธตฺวา ปเปฺปาเสตฺวา อติหาเรตฺวา
ยถาปญฺญตฺตํ ปญฺเปตพฺพา ลิสีทนปจฺจตฺถรณาทิ ปิตาเปตฺวา
สาเธตฺวา ปเปฺปาเสตฺวา อติหาเรตฺวา ยถาปญฺญตฺตํ ปญฺ-
เปตพฺพา ขาทนียาทิ ปิตาเปตฺวา ปมชฺชิตฺวา อติหาเรตฺวา
ยถาฐาเน ปเปตพฺพา อปเรสุ ทิวเสสุ ปิตาเปตฺวา

๑-๒-๓ ปเปฺปาเสตฺวาติปิ ปาโฐ ๆ

មានពណ៌សៅហ្មង ត្រូវជ្រលក់សម្ពត់ហើយពូតរួចសឹមជូត បើផ្ទៃគេមិនបានលាបអ្វីទេ ត្រូវប្រស់ទឹកហើយសឹមជូត សន្ធិវិហារកត្រូវប្រមែប្រមូលសម្រាមយកទៅចោលកន្លែងដ៏សមគួរដោយគិតថា វិហារកុំប្រឡាក់ប្រឡូសដោយធូលីឡើយ គ្រឿងកម្រាលផែនដី ដែលសន្ធិវិហារកហាលជម្រះគោះហើយ ត្រូវនាំយកមកក្រាលដូចដើមវិញ ទ្រនាប់គ្រែដែលសន្ធិវិហារកយកទៅហាលថ្ងៃហើយជូតរួចត្រូវយកមកដម្កល់ទុកកន្លែងដដែល គ្រែដែលសន្ធិវិហារកហាលថ្ងៃជម្រះគោះរួច ត្រូវធ្វើឲ្យខាបស្រួលកុំឲ្យខ្ពង្គិចខ្ពង្គុកផែនដី កុំឲ្យប៉ះសន្ធះទ្វារនឹងក្របទ្វារ ហើយនាំយកមកដាក់រៀបចំទុកឲ្យល្អដូចពីដើមវិញ តាំងដែលសន្ធិវិហារកហាលថ្ងៃហើយជម្រះគោះហើយត្រូវធ្វើឲ្យខាបស្រួលកុំឲ្យខ្ពង្គិចខ្ពង្គុកនឹងផែនដី កុំឲ្យប៉ះសន្ធះទ្វារនឹងក្របទ្វារហើយនាំយកទៅដាក់រៀបចំឲ្យល្អដូចពីដើមវិញ ពួកនឹងទៀតដែលសន្ធិវិហារកហាលជម្រះគោះហើយ ត្រូវនាំយកមករៀបចំឲ្យដូចពីដើមវិញ កម្រាលសម្រាប់អង្គុយដែលសន្ធិវិហារកហាលជម្រះគោះហើយត្រូវនាំយកមកក្រាលឲ្យដូចពីដើមវិញ កន្ទោរដែលសន្ធិវិហារកហាលថ្ងៃហើយជូតហើយនាំយកមកដម្កល់ទុកដូចដែលវិញ ផែនក្តារសម្រាប់ផ្អែក ដែលសន្ធិវិហារកហាលថ្ងៃហើយនឹងជូតហើយ ត្រូវនាំមកដម្កល់

ปมฌานสฺส អតិមหนฺตสฺส យថาហានេ ឋបេតព្ពំ បត្តចីវរំ ឧក្ខិ-
បិតព្ពំ បត្តំ ឧក្ខិបន្តេន ឯកេន ហត្ថេន បត្តំ គហេត្វា
ឯកេន ហត្ថេន ហេដ្ឋាមញ្ចំ ឯ ហេដ្ឋាបីឋំ ឯ បហមសិត្វា
បត្តោ ឧក្ខិបិតព្ពោ ន ច អនន្តរហិតាយ ភូមិយា ឋបេត្តោ
ឧក្ខិបិតព្ពោ ចីវរំ ឧក្ខិបន្តេន ឯកេន ហត្ថេន ចីវរំ គហេ-
ត្វា ឯកេន ហត្ថេន ចីវរវំសំ ឯ ចីវរដ្ឋុំ ឯ បមជ្ជិត្វា ចារេតា
អន្តំ ឱរេតា កោតំ កត្វា ចីវរំ ឧក្ខិបិតព្ពំ ។ សចេ បុរត្ថិមា
សរជា ឯតា ឯយន្តិ បុរត្ថិមា ឯតចានា ជវេតព្ពា សចេ
បច្ឆិមា សរជា ឯតា ឯយន្តិ បច្ឆិមា ឯតចានា ជវេតព្ពា
សចេ ឧត្តរ សរជា ឯតា ឯយន្តិ ឧត្តរ ឯតចានា
ជវេតព្ពា សចេ ទក្ខិណា សរជា ឯតា ឯយន្តិ ទក្ខិ-
ណា ឯតចានា ជវេតព្ពា សចេ សីតកាលោ ហោតិ
ឆវ ឯតចានា វិវិតព្ពា រត្តិ ជវេតព្ពា សចេ ឧណ្ហា-
កាលោ ហោតិ ឆវ ឯតចានា ជវេតព្ពា រត្តិ វិវិ-
តព្ពា ។ សចេ បរិវេណំ ឧក្ការបំ ហោតិ បរិវេណំ សម្មជ្ជិ-
តព្ពំ សចេ កោដ្ឋកោ ឧក្ការចោ ហោតិ កោដ្ឋកោ
សម្មជ្ជិតព្ពោ សចេ ឧបដ្ឋានសាលា ឧក្ការចា ហោតិ

ទុកដូចដៃលវិញ ឬគ្រែនឹងចីវរសន្ធិវិហារិកត្រូវដម្កល់ទុក កាលយកឬគ្រែ
ទៅទុកដាក់ត្រូវកាន់ឬគ្រែដោយដៃម្ខាង ហើយយកដៃម្ខាងស្ទាបមើលទី
ខាងក្រោមនៃជើងគ្រែក្តី ទីខាងក្រោមនៃតាំងក្តី ហើយសឹមទុកឬគ្រែចុះ មិន
ត្រូវទុកឬគ្រែលើទីមិនសមគួរឡើយ កាលយកចីវរទៅទុក ត្រូវកាន់
ចីវរដោយដៃម្ខាង យកដៃម្ខាងជួតស្បៃងចីវរក្តី ខ្សែចីវរក្តី ហើយបត់
ជាយខាងណោះឲ្យជាផ្នត់ចូលមកខាងណោះ (គឺបត់ចីវរជាពីរ) ហើយដម្កល់
ទុកនូវចីវរចុះ ។ បើខ្សល់បក់ពីងធួលីមកអំពីទិសខាងកើត សន្ធិវិហារិក
ត្រូវបិទបង្អួចទិសខាងកើត បើខ្សល់បក់ពីងធួលីមកពីទិសខាងឦសាន សន្ធិវិ-
ហារិកត្រូវបិទបង្អួចទិសខាងឦសាន បើខ្សល់បក់ពីងធួលីមកពីទិសខាងជើង
សន្ធិវិហារិកត្រូវបិទបង្អួចទិសខាងជើង បើខ្សល់បក់ពីងធួលីមកពីទិសខាង
ត្បូង សន្ធិវិហារិកត្រូវបិទបង្អួចទិសខាងត្បូង បើកាលគឺរដូវត្រជាក់ សន្ធិវិ-
ហារិកត្រូវបើកបង្អួចកងវេលាថ្ងៃ ត្រូវបិទកងវេលាយប់ បើកាលគឺរដូវក្តៅ
សន្ធិវិហារិកត្រូវបិទបង្អួចកងវេលាថ្ងៃ ត្រូវបើកកងវេលាយប់ ។ បើបរិវេណ
មានសម្រាម សន្ធិវិហារិកត្រូវជ្រោសបរិវេណ បើបន្ទប់មានសម្រាម សន្ធិ-
វិហារិកត្រូវជ្រោសបន្ទប់ បើឧបដ្ឋានសាលា[1]មានសម្រាម សន្ធិវិហារិក

---

១ ភោជនដាន់ ។

อุปชฺฌายสาลา สมฺมุขีภูตา สเจ อกฺกนิสาลา อุกฺกาชา
โหติ อกฺกนิสาลา สมฺมุขีภูตา สเจ วจฺจกุฏี อุกฺกาชา
โหติ วจฺจกุฏี สมฺมุขีภูตา สเจ ชานิยํ น โหติ
ชานิยํ อุปชฺฌายเตฺวา สเจ ปริโภชนียํ น โหติ
ปริโภชนียํ อุปชฺฌายเตฺวา สเจ อาจมนกุมฺภิยา อุ-
ทกํ น โหติ อาจมนกุมฺภิยา อุทกํ อาสิญฺจิตเฺวา ฯ
สเจ อุปชฺฌายสฺส อนภิรติ อุปฺปชฺชา โหติ สทฺธิวิ-
หาริเกน รูปกายสเตฺถน รูปกายสาเยตเฺวา ธมฺมกถา
กาสฺส กาตพฺพา สเจ อุปชฺฌายสฺส กุกฺกุจฺจ อุปฺปชฺชิ
โหติ สทฺธิวิหาริเกน วินเยน วินโย ธาเยตพฺโพ ธมฺม-
กถา กาสฺส กาตพฺพา สเจ อุปชฺฌายสฺส ทิฏฺฐิคตํ
อุปฺปชฺชิ โหติ สทฺธิวิหาริเกน วิเวเจตพฺโพ วิเวจาเยตพฺโพ
ธมฺมกถา กาสฺส กาตพฺพา ฯ สเจ อุปชฺฌายา กรุ-
ณมฺหิ อชฺฌาปชฺชา โหติ ปริกาสารโห สทฺธิวิหาริเกน
อุสฺสุกฺกิ กาตพฺโพ กถินฺติ นุ โข สเงฺฆ อุปชฺฌายสฺส
ปริกาสิ ธเรยฺยาติ สเจ อุปชฺฌายา มูลาย

ត្រូវបោសឧបដ្ឋានសាលា បើភេងក្តៅងមានសម្រាម សន្ធិវិហារិកត្រូវបោសភេងក្តៅង បើបង្គន់មានសម្រាម សន្ធិវិហារិកត្រូវបោសបង្គន់ បើទឹកឆាន់មិនមាន សន្ធិវិហារិកត្រូវដំកល់ទឹកឆាន់ បើទឹកសម្រាប់ប្រើប្រាស់មិនមាន សន្ធិវិហារិកត្រូវដំកល់ទឹកសម្រាប់ប្រើប្រាស់ បើទឹកមិនមានក្នុងភ្នមសម្រាប់ដម្រះអាចមន៍ សន្ធិវិហារិកត្រូវចាក់ទឹកដាក់ក្នុងភ្នមសម្រាប់ដម្រះអាចមន៍ ។ បើសេចក្តីអង្គុកកើតឡើងដល់ឧបដ្ឋាយ៍ សន្ធិវិហារិកត្រូវនាំឧបដ្ឋាយ៍ចៀសចេញទៅកំសាន្តដោយខ្លួនឯង ឬឲ្យភិក្ខុដទៃនាំចៀសចេញទៅកំសាន្ត[1] មិ៉ាងទៀត សន្ធិវិហារិកត្រូវធ្វើធម្មកថាដល់ឧបដ្ឋាយ៍នោះ បើឧបដ្ឋាយ៍មានសេចក្តីសង្ស័យកើតឡើង សន្ធិវិហារិកត្រូវបន្ទោបង់សេចក្តីសង្ស័យនោះដោយខ្លួនឯង ឬឲ្យភិក្ខុដទៃបន្ទោបង់ក៏បាន ឬត្រូវធ្វើធម្មកថាដល់ឧបដ្ឋាយ៍នោះ បើសេចក្តីយល់ខុសកើតឡើងដល់ឧបដ្ឋាយ៍ សន្ធិវិហារិកត្រូវដោះស្រាយសេចក្តីយល់ខុសនោះចេញដោយខ្លួនឯង ឬឲ្យភិក្ខុដទៃដោះស្រាយសេចក្តីយល់ខុសនោះចេញក៏បាន ឬត្រូវធ្វើធម្មកថាដល់ឧបដ្ឋាយ៍នោះ ។ បើឧបដ្ឋាយ៍ត្រូវគុំកាបត្តិគួរដល់បរិវាស សន្ធិវិហារិកត្រូវធ្វើសេចក្តីខ្វល់ខ្វាយដោយគិតថា សង្ឃគប្បីឲ្យបរិវាសដល់ឧបដ្ឋាយ៍(របស់អញ)ដោយឧបាយដូចម្តេចហ្ន៎ បើឧបដ្ឋាយ៍

---

១ អដ្ឋកថា ថា សន្ធិវិហារិកត្រូវនាំឧបដ្ឋាយ៍ទៅទីដទៃក្តី ឲ្យភិក្ខុដទៃនាំទៅក្តី ដើម្បីបន្ទោបង់សេចក្តីអង្គុកនៃឧបដ្ឋាយ៍ ។

បដិកស្សជារហោ ហោតិ សន្ធិវិហារិកេន ឧស្សុក្កំ
ការេតព្ពំ កាតព្ពំ ន្តុ ខោ សង្ឃោ ឧបជ្ឈាយំ ម្ហលាយ
បដិកស្សេយ្យាតិ សចេ ឧបជ្ឈាយោ មានត្តារហោ
ហោតិ សន្ធិវិហារិកេន ឧស្សុក្កំ ការេតព្ពំ កាតព្ពំ ន្តុ
ខោ សង្ឃោ ឧបជ្ឈាយស្ស មានត្តំ ទាតេយ្យាតិ សចេ
ឧបជ្ឈាយោ អព្ភានារហោ ហោតិ សន្ធិវិហារិកេន
ឧស្សុក្កំ ការេតព្ពំ កាតព្ពំ ន្តុ ខោ សង្ឃោ ឧបជ្ឈាយំ
អព្ភេយ្យាតិ ។ សចេ សង្ឃោ ឧបជ្ឈាយស្ស កម្មំ
ការេតុការាមោ ហោតិ តជ្ជនីយំ វា និយស្សំ វា បព្ពាជ-
នីយំ វា បដិសារណីយំ វា ឧក្ខេបនីយំ វា សន្ធិវិហា-
រិកេន ឧស្សុក្កំ ការេតព្ពំ កាតព្ពំ ន្តុ ខោ សង្ឃោ ឧបជ្ឈា-
យស្ស កម្មំ ន ការេយ្យ លហុការាយ វា បរិណា-
មេយ្យាតិ ការំ វា បនស្ស ហោតិ សង្ឃេន កម្មំ
តជ្ជនីយំ វា និយស្សំ វា បព្ពាជនីយំ វា បដិសារណីយំ

គួរដល់តិរិយាទាញអន្តរាបត្តិ(១)មកដាក់កន្លងមូលាបត្តិ(២) សន្ធិវិហារិកត្រូវ
ធ្វើនូវសេចក្តីឆ្ងល់ខ្វាយដោយគិតថា សង្ឃនឹងទាញអន្តរាបត្តិមកដាក់កន្លងមូ-
លាបត្តិចំពោះឧបជ្ឈាយ៍ដោយឧបាយដូចម្តេចហ្ន៎ បើឧបជ្ឈាយ៍គួរដល់មា-
នត្ត សន្ធិវិហារិកត្រូវធ្វើនូវសេចក្តីឆ្ងល់ខ្វាយដោយគិតថា សង្ឃគប្បីឲ្យមា-
នត្តដល់ឧបជ្ឈាយ៍ដោយឧបាយដូចម្តេចហ្ន៎ បើឧបជ្ឈាយ៍គួរដល់អព្ភានកម្ម
សន្ធិវិហារិកត្រូវធ្វើនូវសេចក្តីឆ្ងល់ខ្វាយដោយគិតថា សង្ឃនឹងឲ្យអព្ភានកម្ម
ចំពោះឧបជ្ឈាយ៍ដោយឧបាយដូចម្តេចហ្ន៎ ។ បើសង្ឃមានសេចក្តីត្រិះថា
ដើម្បីធ្វើនូវកម្មគឺ តជ្ជនីយកម្មក្តី និយស្សកម្មក្តី បព្ពាជនីយកម្មក្តី បដិ-
សារណីយកម្មក្តី ឧក្ខេបនីយកម្មក្តី(៣) ដល់ឧបជ្ឈាយ៍ សន្ធិវិហារិកត្រូវ
ធ្វើនូវសេចក្តីឆ្ងល់ខ្វាយដោយគិតថា សង្ឃកុំគប្បីធ្វើកម្មដល់ឧបជ្ឈាយ៍ ឬ
សង្ឃគប្បីបង្អោនទៅដើម្បីកម្មស្រាលដោយឧបាយដូចម្តេចហ្ន៎ ម្យ៉ាងទៀត
តជ្ជនីយកម្មក្តី និយស្សកម្មក្តី បព្ពាជនីយកម្មក្តី បដិសារណីយកម្មក្តី

---

១ អន្តរាបត្តិ សំដៅយកគរុកាបត្តិដែលភិក្ខុត្រូវក្នុងវេលាកំពុងប្រែព្រឹត្តវត្តបរិវាស ។ ២ មូលបត្តិ សំដៅយកគរុកាបត្តិដែលភិក្ខុត្រូវមកពីខាងដើម សេចក្តីថា ភិក្ខុកំពុងប្រែព្រឹត្តបរិវាសមកច្រើនថ្ងៃហើយ ។ ត្រូវគរុកាបត្តិណាមួយទៀតដោយចិនដាំងទុក្ខនោះ សង្ឃត្រូវលុបថ្ងៃដែលបានប្រែព្រឹត្តវត្តមកហើយនោះចេញ តាំងឲ្យប្រែព្រឹត្តវត្តរាប់ថ្ងៃជាថ្មីទៅទៀត ។ ៣ កម្មទាំង ៥យ៉ាងនេះនឹងមានសំដែងដោយពិស្តារក្នុងកម្មក្ខន្ធកៈតទៅខាងមុខ ។

ก ฯเปฯ ปณฺเณ ก สทฺธิวิหาริเกน ฯสฺสกฺกา คาตพฺพา กิจฺจา ฯ ขา ฯปชฺฌายา สมฺมาวตฺตยฺย โลมา ฯาตยฺย นฺหารีวตฺตยฺย สเจฺจ ตา กมฺมา ปฏิปฺปสฺสมฺภยฺยาติ ฯ สเจ ฯปชฺฌายสฺส จีวรา ฯาวิตพฺพา ฯหาติ สทฺธิวิหาริเกน ฯาวิตพฺพา ฯสฺสกฺกา ก คาตพฺพา กิจฺจา ฯ ขา ฯปชฺฌายสฺส จีวรา ฯาวิยาติ สเจ ฯปชฺฌายสฺส จีวรา คาตพฺพา ฯหาติ สทฺธิวิหาริเกน คาตพฺพา ฯสฺสกฺกา ก คาตพฺพา กิจฺจา ฯ ขา ฯปชฺฌายสฺส จีวรา กริยาติ สเจ ฯปชฺฌายสฺส ฯณา ปจิตพฺพา ฯหาติ สทฺธิวิหาริเกน ปจิตพฺพา ฯสฺสกฺกา ก คาตพฺพา กิจฺจา ฯ ขา ฯปชฺฌายสฺส ฯณา ปจิยาติ สเจ ฯปชฺฌายสฺส จีวรา ฯเณา[๑] ฯหาติ สทฺธิวิหาริเกน ฯเณา ฯสฺสกฺกา ก คาตพฺพา กิจฺจา ฯ ขา ฯปชฺฌายสฺส จีวรา ฯณิยาติ จีวรา ฯเณฺณ[๒] สาขุกา สมฺมาวตฺตกา สมฺมาวตฺตกา ฯเณา ฯ ฉ ฯปชฺฌายา อนาปุจฺฉา ฯกฺกมฺมสฺส

๑ ฉ. ฯเณา ฯ ๒ ฉ. ฯเณฺณ ฯ

ទុក្ខៃបន្ទីយកម្មក្តី ដែលសង្ឃបានធ្វើដល់ឧបជ្ឈាយ៍ហើយ សទ្ធិវិហារិក
ត្រូវធ្វើសេចក្តីខ្វល់ខ្វាយដោយគិតថា ធ្វើដូចម្តេចហ្ន៎ ឲ្យឧបជ្ឈាយ៍របស់អញ
លោកប្រព្រឹត្តល្អទៅ គប្បីសំឡេចភេម (កុំប្រកែកប្រកាន់) គប្បីប្រព្រឹត្តវត្ត
គួរដល់កិរិយារលាស់ចេញចាកកម្ម សង្ឃគប្បីរម្ងាប់កម្មនោះចេញ (ដោយ
ស្រួល) ។ បើចីវរបស់ឧបជ្ឈាយ៍គួរនឹងលាង សទ្ធិវិហារិកត្រូវលាង ឬត្រូវ
ធ្វើនូវសេចក្តីខ្វល់ខ្វាយដោយគិតថា ធ្វើដូចម្តេច នឹងឲ្យគេលាងចីវរ
របស់ឧបជ្ឈាយ៍ បើចីវរបស់ឧបជ្ឈាយ៍គួរធ្វើ (មានប៉ះដេរជាដើម) សទ្ធិ-
វិហារិកគប្បីធ្វើប្រគេន ឬត្រូវធ្វើសេចក្តីខ្វល់ខ្វាយដោយគិតថា ធ្វើម្តេចហ្ន៎
នឹងឲ្យគេធ្វើចីវរប្រគេនឧបជ្ឈាយ៍ (របស់អញ) បើគ្រឿងជ្រលក់របស់
ឧបជ្ឈាយ៍គួរចំអិន សទ្ធិវិហារិកគប្បីចំអិនប្រគេន ឬត្រូវធ្វើសេចក្តីខ្វល់-
ខ្វាយថា ធ្វើម្តេចហ្ន៎ ជនណាមួយគេនឹងចំអិនទឹកជ្រលក់ប្រគេនឧបជ្ឈាយ៍
បើចីវរបស់ឧបជ្ឈាយ៍គួរជ្រលក់ សទ្ធិវិហារិកគប្បីជ្រលក់ ឬត្រូវធ្វើសេចក្តី
ខ្វល់ខ្វាយថា ធ្វើម្តេចហ្ន៎ ជនណាមួយគប្បីជ្រលក់ចីវរបស់ឧបជ្ឈាយ៍
កាលនឹងជ្រលក់ចីវរត្រូវប្រែត្រឡប់ជ្រលក់ឲ្យសព្វល្អ បើដំណក់ទឹកមិន
ទាន់ដាច់ទេ សទ្ធិវិហារិកមិនត្រូវចៀសចេញទៅឡើយ ។ សទ្ធិវិហារិកមិន
បានច្រាប់ឧបជ្ឈាយ៍ មិនត្រូវឲ្យបាត្រដល់កំភួតខ្នះ (កំភួតដែលមិនត្រូវនឹង

បត្តោ ឆាតព្ពោ ន ឯកច្ចស្ស បត្តោ បដិក្កុ-
តព្ពោ ន ឯកច្ចស្ស ចីវរំ ឆាតព្ពំ ន ឯកច្ចស្ស ចីវរំ
បដិក្កុតព្ពំ ន ឯកច្ចស្ស បរិក្ខារោ ឆាតព្ពោ ន
ឯកច្ចស្ស បរិក្ខារោ បដិក្កុតព្ពោ ន ឯកច្ចស្ស
កេសា ឆេទេតព្ពា ន ឯកច្ចេន កេសា ឆេទាបេតព្ពា ន
ឯកច្ចស្ស បរិកម្មំ កាតព្ពំ ន ឯកច្ចេន បរិកម្មំ កា-
រាបេតព្ពំ ន ឯកច្ចស្ស វេយ្យាវច្ចោ កាតព្ពោ ន
ឯកច្ចេន វេយ្យាវច្ចោ ការាបេតព្ពោ ន ឯកច្ចស្ស
បច្ឆាសមណេន ហោតព្ពំ ន ឯកច្ចោ បច្ឆាសមណោ
អាឆាតព្ពោ ន ឯកច្ចស្ស បិណ្ឌចារោ នីហរិតព្ពោ ន
ឯកច្ចេន បិណ្ឌចារោ នីហារាបេតព្ពោ ។ ន ឧបជ្ឈាយំ
អនាបុច្ឆា គាមោ បវិសិតព្ពោ ន សុសានំ គន្តព្ពំ ន
ទិសា បក្កមិតព្ពា ។ សចេ ឧបជ្ឈាយោ តិលាភោ
ហោតិ យាវដីវំ ឧបដ្ឋាតព្ពោ វុដ្ឋានស្ស អាគមេតព្ពន្តិ ។

ឧបជ្ឈាយ៍)ទេ មិនត្រូវទទួលយកជាត្រវបស់កិកុ្ខពួកខ្លះទេ មិនត្រូវឲ្យចីវរ
ដល់កិកុ្ខពួកខ្លះទេ មិនត្រូវទទួលយកចីវរបស់កិកុ្ខពួកខ្លះទេ មិនត្រូវឲ្យ
គ្រឿងបរិក្ខារដល់កិកុ្ខពួកខ្លះទេ មិនត្រូវទទួលយកគ្រឿងបរិក្ខារបស់កិកុ្ខ
ពួកខ្លះទេ មិនត្រូវកោរសក់ដល់កិកុ្ខពួកខ្លះទេ មិនត្រូវឲ្យកិកុ្ខពួកខ្លះកោរសក់
ឲ្យទេ មិនត្រូវធ្វើបរិកម្មដល់កិកុ្ខពួកខ្លះទេ មិនត្រូវញ៉ាំងកិកុ្ខពួកខ្លះឲ្យធ្វើបរិ-
កម្មទេ មិនត្រូវធ្វើសេចក្តីខ្វល់ខ្វាយបម្រើដល់កិកុ្ខពួកខ្លះទេ មិនត្រូវញ៉ាំងកិកុ
ពួកខ្លះឲ្យធ្វើសេចក្តីខ្វល់ខ្វាយបម្រើខ្លួនទេ មិនត្រូវធ្វើជាបច្ចាសមណៈនៃកិកុ
ពួកខ្លះទេ មិនត្រូវយកកិកុ្ខពួកខ្លះជាបច្ចាសមណៈទេ មិនត្រូវនាំយកបិណ្ឌ-
បាតឲ្យដល់កិកុ្ខពួកខ្លះទេ មិនត្រូវញ៉ាំងកិកុ្ខពួកខ្លះ ឲ្យនាំយកបិណ្ឌបាត
មកឲ្យទេ ។ សទ្ធិវិហារិកមិនបានលាឧបជ្ឈាយ៍ មិនត្រូវចូលទៅកាន់ស្រុក
ទេ មិនត្រូវទៅកាន់នៃគមស្មសានទេ មិនត្រូវច្រៀសចេញទៅកាន់ទិស
ឡើយ ។ បើឧបជ្ឈាយ៍មានជម្ងឺ សទ្ធិវិហារិកត្រូវបម្រើអស់មួយជីវិត ត្រូវ
ធ្វើចាំត្រាតែឧបជ្ឈាយ៍ចេញចាកអាពាធ (គឺត្រូវគ្រាជម្ងឺដកបង់ជា) ។

ចប់ ឧបជ្ឈាយវត្ត ។

[៨២] ឧបជ្ឈាយេន តិក្ខត្តុំ សង្ឃិវិហារកម្ហិ សម្មាវត្តិតព្ពំ ។ តត្រាយំ សម្មាវត្តនា ។ ឧបជ្ឈាយេន តិក្ខត្តុំ សង្ឃិវិហារិកោ សង្គហោតព្ពោ អនុគ្គហោតព្ពោ ឧទ្ទេសេន បរិបុច្ឆាយ ឱវាទេន អនុសាសនិយា ។ សចេ ឧបជ្ឈាយស្ស បត្តោ ហោតិ សង្ឃិវិហារិកស្ស បត្តោ ន ហោតិ ឧបជ្ឈាយេន សង្ឃិវិហារិកស្ស បត្តោ ឱនាតព្ពោ ឧស្សុក្កំ វា កាតព្ពំ កិន្តិ ន្តុ ខោ សង្ឃិវិហារិកស្ស បត្តោ ឧប្បជ្ជិយេថាតិ សចេ ឧបជ្ឈាយស្ស ចីវរំ ហោតិ សង្ឃិវិហារិកស្ស ចីវរំ ន ហោតិ ឧបជ្ឈាយេន សង្ឃិវិហារិកស្ស ចីវរំ ឱនាតព្ពំ ឧស្សុក្កំ វា កាតព្ពំ កិន្តិ ន្តុ ខោ សង្ឃិវិហារិកស្ស ចីវរំ ឧប្បជ្ជិយេថាតិ សចេ ឧបជ្ឈាយស្ស បរិក្ខារោ ហោតិ សង្ឃិវិហារិកស្ស បរិក្ខារោ ន ហោតិ ឧបជ្ឈាយេន សង្ឃិវិហារិកស្ស បរិក្ខារោ ឱនាតព្ពោ ឧស្សុក្កំ វា កាតព្ពំ កិន្តិ ន្តុ ខោ សង្ឃិវិហារិកស្ស បរិក្ខារោ ឧប្បជ្ជិយេថាតិ ។ សចេ សង្ឃិវិហារិកោ តិលាឆោ ហោតិ ការាសេស្សវ ឧដ្ឋាយ[1] ឆន្ទកដ្ឋំ ឱនាតព្ពំ មុខោទកំ

---

១ វុដ្ឋាយាតិបិ ឯកេ ទិស្សតិ ។

(៨២) ម្នាលភិក្ខុទាំងឡាយ ឧបដ្ឋាយ៍ត្រូវប្រែព័ត្តឲ្យស្រួលល្អនឹងសន្ថិវិហារិក ។ ឯការដែលប្រែព័ត្តឲ្យស្រួលល្អនឹងសន្ថិវិហារិកនោះ (ដូចសេចក្តីតទៅនេះ) ។ ម្នាលភិក្ខុទាំងឡាយ ឧបដ្ឋាយ៍ត្រូវសង្រ្កាះ (ត្រូវទំនុកបំរុង) ត្រូវអនុគ្រោះ (អាណិតអាសូរ) សន្ថិវិហារិកដោយការបង្រៀនបាលី ដោយអដ្ឋកថា (ពន្យល់នូវសេចក្តីនៃបាលី) ដោយឲ្យដម្ងូនាន (ដោយសេចក្តីពន្យល់ការខុសត្រូវជាមុន) ដោយពាក្យប្រៀនប្រដៅ (ដោយពាក្យរំលឹកជាស់តឿនរឿយៗ) ។ បើឧបដ្ឋាយ៍មានបាត្រ សន្ថិវិហារិកគ្មានបាត្រ ត្រូវឧបដ្ឋាយ៍ឲ្យបាត្រទៅសន្ថិវិហារិក (ប្រើប្រាស់ខ្ទះផង) ម្យ៉ាងទៀត ឧបដ្ឋាយ៍ត្រូវធ្វើសេចក្តីឲ្យល់ឲ្យាយថា ធ្វើម្តេចហ្ន៎សន្ថិវិហារិកនឹងមានបាត្រ បើឧបដ្ឋាយ៍មានចីវរ សន្ថិវិហារិកគ្មានចីវរ ត្រូវឧបដ្ឋាយ៍ឲ្យចីវរទៅសន្ថិវិហារិក (ប្រើប្រាស់ខ្ទះផង) ម្យ៉ាងទៀត ឧបដ្ឋាយ៍ត្រូវធ្វើសេចក្តីឲ្យល់ឲ្យាយថា ចីវរបស់សន្ថិវិហារិកគប្បីកើតឡើងដូចម្តេចហ្ន៎ បើឧបដ្ឋាយ៍មានគ្រឿងបរិក្ខារ សន្ថិវិហារិកគ្មានគ្រឿងបរិក្ខារ ត្រូវឧបដ្ឋាយ៍ឲ្យគ្រឿងបរិក្ខារទៅសន្ថិវិហារិក (ប្រើប្រាស់ខ្ទះផង) ម្យ៉ាងទៀត ឧបដ្ឋាយ៍ត្រូវធ្វើសេចក្តីឲ្យល់ឲ្យាយថា គ្រឿងបរិក្ខារបស់សន្ថិវិហារិកគប្បីកើតឡើងដោយឧបាយដូចម្តេចហ្ន៎ ។ បើសន្ថិវិហារិកឈឺ ឧបដ្ឋាយ៍ត្រូវក្រោកពីព្រឹកឲ្យឈើសូន

ធាតុំ អាសនំ បញ្ញាបេតុំ សចេ យាគុ ហោតិ ភាជនំ
ធោវិត្វា យាគុ ឧបនាមេតព្វា យាគុំ បីតស្ស ឧទកំ
ទត្វា ភាជនំ បដិក្កហេត្វា នីចំ កត្វា សាធុកំ អបរិ-
ឃំសន្តេន ធោវិត្វា បដិសាមេតុំ សន្ទិដ្ឋោ សម្ភត្ថោ
អាសនំ ឧទ្ធរិតុំ សចេ សោ ទេសោ ឧក្កាទោ ហោតិ
សោ ទេសោ សម្មជ្ជិតព្វោ ។ សចេ សន្ទិដ្ឋោ សម្ភត្ថោ
តាទិ បរិសិត្តកាមោ ហោតិ ឯវាសនំ ធាតុំ បដិនិវា-
សនំ បដិក្កហេតុំ កាយពន្ធនំ ធាតុំ សកុណា
កត្វា សង្ឃាដិយោ ធាតព្វា ធោវិត្វា បត្តោ សុធ-
កោ[1] ធាតព្វោ ឯត្តាវតា ឯវត្តិស្សតីតិ អាសនំ បញ្ញា-
បេតុំ ចាធោធកំ ចាធបីឋំ ចាធកថលិកំ ឧបនិក្ខិ-
បិតុំ បច្ចុក្កដ្ឋា បត្តចីវរំ បដិក្កហេតុំ បដិនិវាសនំ
ធាតុំ ឯវាសនំ បដិក្កហេតុំ ។ សចេ ចីវរំ សិន្នំ
ហោតិ មុហុត្តំ ឧណ្ហោ ឯតាយេតុំ ន ច ឧណ្ហោ ចីវរំ
ឯធហិតុំ ចីវរំ សំហរិតុំ ចីវរំ សំហរន្តេន ចតុរង្គុលំ

---

១ សោទកោតិបិ ពាហោ ទិស្សតិ ។

ឲ្យទឹកលុបមុខ ក្រែលអាសនៈបើមានបបរ ត្រូវឧបជ្ឈាយ៍លាងកាដន៍ហើយ
ដាក់បបរឲ្យទៅ កាលសទ្ធិវិហារិកដែលឈឺនោះហុតទឹកបបររួចហើយ
ឧបជ្ឈាយ៍ត្រូវហុចទឹកឲ្យ រួចទទួលយកកាដន៍មកវិញដោយស្រួលបួលកុំ
ឲ្យទង្គិចទង្គឹកឡើយរួចលាងរៀបទុកដាក់ឲ្យល្អ កាលបើសទ្ធិវិហារិកក្រែក
ចេញហើយ ឧបជ្ឈាយ៍ត្រូវរើអាសនៈចេញ បើកន្លែងនោះស្មោកគ្រោក
ឧបជ្ឈាយ៍ត្រូវបោសកន្លែងនោះចេញ ។ បើសទ្ធិវិហារិកមានជ្រាថ្នាន់ចូល
ទៅកាន់ស្រុក ឧបជ្ឈាយ៍ត្រូវឲ្យស្បង់សម្រាប់ស្លៀកទៅ ទទួលយកស្បង់
បន្ទាស់នោះមកវិញ ត្រូវឲ្យកាយពន្ធគឺវត្តពន្ធបង្កិះ ត្រូវដម្បូតសង្ឃាដិជា
ពីរជាន់ហើយសឹមឲ្យ ត្រូវលាងជាត្រដែលមានទឹកចេញហើយសឹមឲ្យ
ឧបជ្ឈាយ៍ត្រូវគិតថា សទ្ធិវិហារិកមុខជានឹងត្រឡប់មកវិញទៅពេលស្មើនេះ
ហើយក្រែលអាសនៈបម្រុងទុកឲ្យ ត្រូវដំកល់ទឹកលាងដើង តាំងសម្រាប់
រងដើងនឹងក្បឿងសម្រាប់ដូតដើង(១) ត្រូវក្រែកឡើងទៅទទួលជាត្រនឹង
ចីវរ ត្រូវឲ្យស្បង់សម្រាប់ផាស់ ហើយទទួលយកស្បង់ដែលស្លៀកមក
វិញ ។ បើចីវរសើមដោយញើស ឧបជ្ឈាយ៍ត្រូវសំដិលចីវរកន្ធឹកំដៅថ្ងៃ១
ស្របក់ម្យ៉ាងទៀតកុំទុកចីវរកន្ធឹកំដៅថ្ងៃយូរពេក ត្រូវបត់ចីវរ (យកមកទុក)

---

១ បានដំណាលតាំងសម្រាប់រងដើងដែលលាងរួចហើយ គឺតាំងថ្នាក់ខាងលើ ឯក្បឿងសម្រាប់ដូតដើងនោះបានដំណាលតែសម្រាប់ដូតដើងដែលគេមិនត្រូវការលាង គឺរបស់អ្វីដែលគេសម្រាប់ដូត ។

กลฺยาณสมฺปเทสฺวา จีวรํ สมาทาตพฺพนฺติ อาทิมฺหิ วุตฺตนเยน อาจริยสนฺติเก กายพนฺธนาทีนิ กตฺวา ๆ สเจ ปณฺฑิจฺจาทีนิ นตฺถิ สทฺธิวิหาริกสฺส จ อุปชฺฌายกมฺมาทีนิ นตฺถิ อุทกํ ทตฺวา ปณฺฑิจฺจาทีนิ อุปชฺฌายเมตฺวา สทฺธิวิหาริกสฺส จาทิยนฺตสฺส ปุพฺพภาเคว กุลวิสฺสาสนตฺถาย อุทกํ ทตฺวา ปตฺตจีวรปฏิคฺคหณตฺถาย อนุกมฺปาย ฉายูทกสมฺปนฺนฏฺฐานาทีสุ นิสีทาเปตฺวา ปาทธาวนตฺถาย อุทกปฏิคฺคหณตฺถาย จ อุณฺหกาเล ฉายูทกสมฺปนฺนฏฺฐานาทีสุ นิสีทาเปตฺวา ปาทธาวนตฺถาย อุทกปฏิคฺคหณตฺถาย จ ปตฺตจีวรปฏิคฺคหณตฺถาย จ ปาทธาวนตฺถาย จ

กาลเมื่อจะปฏิบัติจีวร ต้องตัดจีวรให้เป็นเศษเล็กเศษน้อยประมาณ ๔ กระทบ แล้วจึงปฏิบัติจีวรด้วยคิดว่า อย่าให้ชักช้าในการปฏิบัติจีวรนานนักเลย แล้วจึงวางไว้ในที่ใกล้ ๆ เมื่ออาหารบิณฑบาตมีแล้ว สัตถุวิหาริกต้องการน้ำดื่ม อุปัชฌายะต้องให้น้ำดื่มแล้วจึงให้อาหารบิณฑบาต อุปัชฌายะต้องถามสัตถุวิหาริกถึงน้ำดื่มว่ามีหรือไม่ ถ้าสัตถุวิหาริกไม่มีน้ำดื่ม อุปัชฌายะต้องให้น้ำดื่ม แล้วจึงรับบาตรจีวรมาเก็บไว้ด้วยตนเอง ครั้นแล้วจึงให้ล้างเท้าแล้วจึงให้ขึ้นสู่อาสนะ ต้องไม่ให้ทำการงานอันหนักในวันนั้นเลย ต้องให้ทำการงานอันเบาบางเท่านั้น ต้องไม่ให้ทำการงานในที่ไกลเลย ต้องไม่ให้ทำการงานในที่ใกล้ ๆ ด้วย ต้องไม่ให้ทำการงานในที่ที่ลมพัดมาถึงด้วย ต้องไม่ให้ทำการงานในที่ที่ควันไฟลอยมาถึงด้วย ต้องไม่ให้ทำการงานในที่ที่ฝนตกถึงด้วย ต้องไม่ให้ทำการงานในที่ที่น้ำค้างตกถึงด้วย ต้องไม่ให้ทำการงานในที่ที่แดดส่องถึงด้วย ต้องไม่ให้ทำการงานในที่ที่ยุงและเหลือบกัดด้วย ต้องไม่ให้ทำการงานในที่ที่สัตว์ร้ายมีราชสีห์เป็นต้นมาถึงด้วย ต้องไม่ให้ทำการงานในที่ที่ผู้หญิงและผู้ชายมาถึงด้วย ต้องไม่ให้ทำการงานในที่ที่ผู้หญิงและผู้ชายเห็นด้วย ต้องไม่ให้ทำการงานในที่ที่ผู้หญิงและผู้ชายได้ยินด้วย ต้องไม่ให้ทำการงานในที่ที่ผู้หญิงและผู้ชายรู้ด้วย ต้องไม่ให้ทำการงานในที่ที่ผู้หญิงและผู้ชายมาพบด้วย ต้องไม่ให้ทำการงานในที่ที่ผู้หญิงและผู้ชายมาเห็นด้วย ต้องไม่ให้ทำการงานในที่ที่ผู้หญิงและผู้ชายมาได้ยินด้วย ต้องไม่ให้ทำการงานในที่ที่ผู้หญิงและผู้ชายมาร

ហោតិ ឧហាន បដិយាទេតព្ពំ សចេ សីតេន អត្ថោ ហោ-
តិ សីតំ បដិយាទេតព្ពំ សចេ ឧណ្ហេន អត្ថោ ហោតិ ឧណ្ហំ
បដិយាទេតព្ពំ ។ សចេ សទ្ធិវិហារិកោ ឧបជ្ឈាយំ បរិសិ-
ញ្ចកាមោ ហោតិ ឧណ្ហំ សន្ថេតព្ពំ មត្តិកា តេមេតព្ពា
ឧបជ្ឈាយបីឋំ អាទាយ កត្តព្ពា ឧបជ្ឈាយបីឋំ ឧត្វា ចីវរំ
បដិក្កហេត្វា ឯកមន្តំ និក្ខិបិតព្ពំ ឧណ្ហំ ឋាតព្ពំ មត្តិកា
ឋាតព្ពា សចេ ខុរប្បហតិ ឧបជ្ឈាយំ បរិសិតព្ពំ ឧបជ្ឈាយំ
បរិសិត្តេន មត្តិកាយ មុខំ មក្ខេត្វា បុរតោ ច បច្ឆតោ
ច បដិច្ឆាទេត្វា ឧបជ្ឈាយំ បរិសិតព្ពំ ន ថេវេ កិក្ខ អនុប្ប-
ទជ្ជ និសីទិតព្ពំ ន ឆវ កិក្ខ អាសនេន បដិពាហោតព្ពា
ឧបជ្ឈាយេ សទ្ធិវិហារិកេស្ស បរិកម្មំ កាតព្ពំ ឧបជ្ឈាយ
និក្ខមន្តេន ឧបជ្ឈាយបីឋំ អាទាយ បុរតោ ច បច្ឆតោ ច
បដិច្ឆាទេត្វា ឧបជ្ឈាយ និក្ខមិតព្ពំ ឧទកេបិ សទ្ធិវិហារិ-
កេស្ស បរិកម្មំ កាតព្ពំ ឧហាតេន បឋមតរំ ឧត្តរិត្វា
អត្តនោ កត្តំ ភេទកំ កត្វា និវាសេត្វា សទ្ធិវិហារិកេស្ស
កត្តតោ ឧទកំ បមដ្ឋិតព្ពំ និវាសនំ ឋាតព្ពំ សង្ឃាដិ

ឧបជ្ឈាយ៍ត្រូវចាត់ចែងទឹកសម្រាប់ឆ្អូតឲ្យ បើសទ្ធិវិហារិកត្រូវការទឹកត្រជាក់ ឧបជ្ឈាយ៍ត្រូវចាត់ចែងទឹកត្រជាក់ឲ្យ បើសទ្ធិវិហារិកត្រូវការទឹកក្តៅ ឧបជ្ឈាយ៍ត្រូវចាត់ចែងទឹកក្តៅឲ្យ ។ បើសទ្ធិវិហារិកចង់ចូលទៅកាន់ភេងក្តើង ឧបជ្ឈាយ៍ត្រូវសូន្យលំអិតសម្រាប់ឆ្អូតទឹកខ្មុក ត្រូវផ្សែមដីស្អិតខ្មុក រួចនាំយកតាំងសម្រាប់ភេងក្តើង ហើយប្រគល់តាំងសម្រាប់ភេងក្តើងទៅសទ្ធិវិហារិក ស្រែចហើយទទួលយកចីវរមកខ្មុកជាក់ដោយឡែក ហើយត្រូវឲ្យគ្រឿងលំអិត ត្រូវឲ្យដីស្អិតទៅសទ្ធិវិហារិក បើឧបជ្ឈាយ៍អាចនឹងចូលទៅកាន់ភេងក្តើង (ផងបាន) គប្បីចូលទៅកាន់ភេងក្តើងចុះ កាលនឹងចូលទៅកាន់ភេងក្តើង ត្រូវយកដីស្អិតលាបមុខរួចបិទបាំងពីខាងមុខខាងក្រោយ ហើយសឹមចូលទៅកាន់ភេងក្តើង មិនត្រូវអង្គុយប្រឹតបៀតបៀតពួកកិកុចាស់ មិនត្រូវហាមពួកកិកុខ្ចីដោយអាសនៈ ឧបជ្ឈាយ៍ត្រូវឆ្លើបរិកម្មដល់សទ្ធិវិហារិកក្នុងភេងក្តើង កាលនឹងចេញពីភេងក្តើងទៅ ត្រូវនាំយកតាំងសម្រាប់ភេងក្តើងចេញហើយបិទបាំងពីខាងមុខខាងក្រោយ រួចសឹមចេញពីភេងក្តើង សូម្បីក្នុងទឹកក៏ឧបជ្ឈាយ៍ត្រូវតែឆ្លើបរិកម្មដល់សទ្ធិវិហារិកដែរ កាលឧបជ្ឈាយ៍ឆ្អូតរួចត្រូវឡើងមកមុនហើយជូតកាយនៃខ្លួនឲ្យស្ងួតទឹកហើយសឹមស្លៀកសង្ឃាដ៍ រួចត្រូវជូតទឹកអំពីកាយរបស់សទ្ធិវិហារិកទៀត ហើយហុចសង្ឃាដ៍សម្រាប់ស្លៀក ហុចសង្ឃាដ៍ទៅឲ្យសទ្ធិវិហារិក

ตาตญฺจ ฉฏฺฐายปิ ปมาทาย ปมชฺชนฺโต อาคนฺตฺวา อาสนฺเน ปญฺญาเปตพฺเพ ตาเทนกาเล ตาทิปิ ตาทกฺขณิกาเล อุปนิกฺขิปิตพฺพา สงฺคีติกาโร ตาทิเยน ปุคฺคเลน ฯ ยสฺมึ วิหาเร สงฺคีติกาโร วิหารเต สเจ สา วิหาเร อุกฺกาเจ โหติ สเจ อุสฺสหติ สาเยเตญฺเญว วิหารา สาเยเตเนน ปมมฺ ปตฺตปีวรา ติกาวสฺสา ฝาสมนฺตา นิกฺขิปิตพฺพา นิสีทนรชฺชุสณฺฐาปนา ติกาวสฺสา ฝาสมนฺตา นิกฺขิปิตพฺพา กิสิติมฺพาหนา ติกาวสฺสา ฝาสมนฺตา นิกฺขิปิตพฺพา มญฺเจ ติเจ กตฺวา สาขุกา อปริยนฺเตน อสงฺฆฏฺเฏนฺเตน กาฬปิฏฺเฐ ติกาวสฺสา ฝาสมนฺตา นิกฺขิปิตญฺเจ ปีฐ ติเจ กตฺวา สาขุกา อปริยนฺเตน อสงฺฆฏฺเฏนฺเตน กาฬปิฏฺเฐ ติกาวสฺสา ฝาสมนฺตา นิกฺขิปิตพฺพา มญฺจปฺปฏิพาหนกา ติกาวสฺสา ฝาสมนฺตา นิกฺขิปิตญฺเจ เขฬมลฺลโก ติกาวสฺสา ฝาสมนฺตา นิกฺขิปิตญฺเจ อปสฺเสนผลกา ติกาวสฺสา ฝาสมนฺตา นิกฺขิปิตพฺพา กุมฺภณฺเฑ ยาคุปญฺจภาชเน สลฺเลขิตฺวา ติกาวสฺสา ฝาสมนฺตา นิกฺขิปิตพฺพา สเจ วิหาเร สนฺถตกา โหติ อุลฺโลกา ปมมฺ ปหาเรตพฺพา

រួចហើយត្រូវនាំយកតាំងសម្រាប់ភេងភ្លើងចេញមកហើយក្រាលអាសនៈចាំជាមុន ឧបជ្ឈាយ៍ត្រូវដំកល់ទឹកសម្រាប់លាងជើង តាំងសម្រាប់រងជើងនឹងក្បឿងសម្រាប់ជូតជើង ត្រូវសួរសទ្ធិវិហារិកអំពីទឹកឆាន់ ។ សទ្ធិវិហារិកនៅកន្លែងវិហារណា បើវិហារនោះស្មុកស្មាគ្រាក បើឧបជ្ឈាយ៍អាចនឹងសំអាតបានគប្បីសំអាតវិហារនោះចេញ កាលនឹងសំអាតវិហារ ត្រូវនាំយកជាតិនឹងចីវរចេញជាមុនទៅទុកកន្លែងដ៏សមគួរ ត្រូវនាំយកកម្រាលសម្រាប់អង្គុយទៅទុក កន្លែងដ៏សមគួរ ត្រូវនាំយកពួកនឹងខ្នើយទៅទុកកន្លែងដ៏សមគួរ ត្រូវបន្ទាបគ្រែឲ្យឆាប កុំឲ្យត្រដុះនឹងផែនដី កុំឲ្យទង្គិចនឹងសន្ទះទ្វារនឹងក្រចទ្វារ ហើយនាំយកចេញឲ្យស្រួលទៅទុកកន្លែងដ៏សមគួរ ត្រូវបន្ទាបតាំងឲ្យឆាប កុំឲ្យត្រដុះនឹងផែនដី កុំឲ្យទង្គិចទង្គុកសន្ទះទ្វារនឹងក្រចទ្វារ ហើយនាំយកចេញឲ្យស្រួលទៅទុកកន្លែងដ៏សមគួរ ត្រូវនាំយកទូនាប់គ្រែទៅទុក កន្លែងដ៏សមគួរ ត្រូវនាំយកកន្ទោរទៅទុកកន្លែងដ៏សមគួរ ត្រូវនាំយកក្តារសម្រាប់ផ្អែកទៅទុក កន្លែងដ៏សមគួរ គ្រឿងកម្រាលផែនដី ត្រូវឧបជ្ឈាយ៍កំណត់ឲ្យចាំកន្លែងដែលគេក្រាលយ៉ាងណា ហើយនាំយកទៅទុក កន្លែងដ៏សមគួរ បើកន្លែងវិហារមានគ្រឿងស្មុកស្មាញ (មានសរសៃពីរជាន់ជាដើម) ត្រូវបោស

អាលោកសង្ខិកណ្ឌកាតា បមជ្ជិតព្វា សចេ តេវុកបរិ-
កម្មកតា កិត្តិ កណ្ណកិតា ហោតិ ចោឡកំ តេមេត្វា
បីឡេត្វា បមជ្ជិតព្វា សចេ កាឡវណ្ណកតា ភូមិ កណ្ណ-
កិតា ហោតិ ចោឡកំ តេមេត្វា បីឡេត្វា បមជ្ជិតព្វា
សចេ អកតា ហោតិ ភូមិ ឧទកេន បរិប្ផោសេត្វា
សម្មជ្ជិតព្វា មា វិហារេ រជេន ឱហញ្ញីតិ សង្ការំ វិចិនិ-
ត្វា ឯកមន្តំ ជន្ទេតព្វំ កុម្មគ្គវណំ ឱតារេត្វា សោធេត្វា
បប្ផោដេត្វា អតិហរិត្វា យថាបញ្ញត្តំ បញ្ញាបេតព្វំ មញ្ច-
ប្បដិភាគតា ឱតារេត្វា បមជ្ជិត្វា អតិហរិត្វា យថា-
ឋានេ ឋបេតព្វា មញ្ចោ ឱតារេត្វា សោធេត្វា បប្ផោ-
ដេត្វា ឆិទ្ទំ កត្វា សាធុកំ អបរិឃំសន្តេន អសង្ឃដ្ដ-
ន្តេន កវាដបិដ្ឋំ អតិហរិត្វា យថាបញ្ញត្តំ បញ្ញាបេតព្វោ
បីឋំ ឱតារេត្វា សោធេត្វា បប្ផោដេត្វា ឆិទ្ទំ កត្វា
សាធុកំ អបរិឃំសន្តេន អសង្ឃដ្ដន្តេន កវាដបិដ្ឋំ
អតិហរិត្វា យថាបញ្ញត្តំ បញ្ញាបេតព្វំ ភិសិពិម្ពោហនំ
ឱតារេត្វា សោធេត្វា បប្ផោដេត្វា អតិហរិត្វា យថា-
បញ្ញត្តំ បញ្ញាបេតព្វំ ឯិសីទនបច្ចត្ថរណំ ឱតារេត្វា

អំពីពិតានចេញជាមុន ហើយត្រូវដួតសំអាតកន្ទៀតជ្រុងសន្ទឹកបង្អួច បើជញ្ជាំងគេលាបដោយវេ៉ ម៉ានមន្ទិលសៅហ្មង ត្រូវជ្រលក់កំណាត់សំពត់ (ក្នុងទឹក) រួចពូតចេញហើយសឹមដួត បើទីដែលគេលាបដោយពណ៌ខ្មៅ ម៉ានមន្ទិលសៅហ្មង ត្រូវផ្សែមកំណាត់សំពត់រួចពូតចេញ ហើយសឹមដួត បើទីដែលមិនបានលាបអ្វីទេ ត្រូវយកទឹកទៅច្រោះសិនហើយសឹមបោសចេញ ត្រូវកំណត់ទុកក្នុងចិត្តថា វិហារមិនត្រូវឲ្យស្មោកគ្រោកដោយធូលីឡើយ ហើយប្រមូលសំរាមយកទៅចាក់ចោលដោយឡែក គ្រឿងកម្រាលផែនដីដែលហាលរួចហើយត្រូវគោះ (ឲ្យស្អាត) រួចនាំយកទៅក្រាលដូចដែលវិញ ទ្រនាប់ដែលហាលរួចត្រូវដួត (ឲ្យស្អាត) ហើយនាំយកទៅទុកនៅទីដដែលវិញ ដែលហាលរួចហើយដុសលាងគោះរួចហើយ ធ្វើឲ្យខាបស្រួលកុំឲ្យត្រដុះនឹងផែនដី កុំឲ្យទង្គិចទង្គិចសន្ទះទ្វារនឹងក្របទ្វារហើយនាំយកទៅរៀបទុកជាក់ដូចដែលវិញ តាំងដែលហាលរួចហើយត្រូវគោះហើយធ្វើឲ្យខាបស្រួលកុំឲ្យត្រដុះនឹងផែនដី កុំឲ្យទង្គិចទង្គិចសន្ទះទ្វារនឹងក្របទ្វារហើយនាំយកទៅរៀបទុកជាក់ដូចដែលវិញ ពូកនឹងខ្នើយដែលហាលរួចហើយត្រូវគោះរួចនាំយកទៅក្រាលដូចដែលវិញ កម្រាលសម្រាប់អង្គុយ

សោឞេត្វា បប្បោឞេត្វា អភិហរិត្វា យាវទត្ថំ បវារេត្វា ទេតិ ទេយ្យធម្មស្ស ចិតាបេត្វា បមជ្ជិត្វា អភិហរិត្វា យថាហានេ ឋបេតព្ពោ អបស្សេនផលកំ ចិតាបេត្វា បមជ្ជិត្វា អភិហរិត្វា យថាហានេ ឋបេតព្ពំ បត្ត-ចីវរំ និក្ខិបិតព្ពំ បត្តំ និក្ខិបន្តេន ឯកេន ហត្ថេន បត្តំ គហេត្វា ឯកេន ហត្ថេន ហេដ្ឋាមញ្ចំ វា ហេដ្ឋា-បីឋំ វា បរាមសិត្វា បត្តោ និក្ខិបិតព្ពោ ន ច អនន្តរ-ហិតាយ ភូមិយា បត្តោ និក្ខិបិតព្ពោ ចីវរំ និក្ខិបន្តេន ឯកេន ហត្ថេន ចីវរំ គហេត្វា ឯកេន ហត្ថេន ចីវរ-សំ វា ចីវរដ្ឋំ វា បមជ្ជិត្វា ចារតោ អន្តំ ពិរតោ កោតំ កត្វា ចីវរំ និក្ខិបិតព្ពំ ។ សចេ បុរត្ថិមា សរជា វាតា វាយន្តិ បុរត្ថិមា វាតថាជា ឋកេតព្ពោ សចេ បច្ឆិមា សរជា វាតា វាយន្តិ បច្ឆិមា វាតថាជា ឋកេតព្ពោ សចេ ឧត្តរា សរជា វាតា វាយន្តិ ឧត្តរា វាតថាជា ឋកេតព្ពោ សចេ ទក្ខិណា សរជា វាតា វាយន្តិ ទក្ខិណា វាតថាជា ឋកេតព្ពោ សចេ សីតកាលោ

ដែលហាលរួចហើយ ត្រូវគោះរួចនាំយកទៅក្រោលទុក ដូចដែលវិញ
កន្ទោដែលហាលរួចហើយ ត្រូវដួតរួចនាំយកទៅទុក ទៅទីដដែលវិញ
ក្តារសម្រាប់ផ្អែកដែលហាលរួចហើយ ត្រូវដួតហើយនាំយកទៅទុកទៅទី
ដដែលវិញ ត្រូវទុកជាត្រនឹងចីវរ (ឲ្យល្អ) កាលនឹងទុកជាត្រ ដៃម្ខាងចាប់
ជាត្រ ដៃម្ខាងស្ទាប់ក្រោមក្រែមក្តារក្រោមតាំងមើលហើយសឹមទុកជាត្រ មិន
ត្រូវទុកជាត្រលើចីវរដែលមិនសមគួរឡើយ កាលនឹងទុកចីវរ ដៃម្ខាងចាប់ចីវរ
ដៃម្ខាងដួតស្បៀងចីវរឬខ្សែចីវរ ហើយបត់ជាយខាងណោះមកខាងណោះ
ឲ្យជាផ្ចត់សិន រួចសឹមទុកចីវរចុះ ។ បើខ្យល់បក់ធូលីមកពីទិសខាងកើត
ឧបជ្ឈាយ៍ត្រូវបិទបង្អួចពីខាងកើត បើខ្យល់បក់ធូលី មកពីទិសខាងឦសាន
ឧបជ្ឈាយ៍ត្រូវបិទបង្អួចពីខាងឦសាន បើខ្យល់បក់ធូលី មកពីទិសខាងជើង
ត្រូវបិទបង្អួចពីខាងជើង បើខ្យល់បក់ធូលីមកពីទិសខាងត្បូង ឧបជ្ឈាយ៍
ត្រូវបិទបង្អួចពីទិសខាងត្បូង បើវស្សាត្រជាក់ ឧបជ្ឈាយ៍ត្រូវបើកបង្អួច

ภิกฺขเว ภิกฺขุนา ปาฏิกงฺขา ทาตพฺพา ปาฏิกงฺขา สเจ อุปชฺฌาโย ภิกฺขเว ภิกฺขุนา ปาฏิกงฺขา ทาตพฺพา ปาฏิกงฺขา ฯ สเจ ปริเวณี อุกฺกาปิตา ภิกฺขเว ปริเวณี สมฺมชฺชิตพฺพา สเจ โกฏฺฐโก อุกฺกาปิโต ภิกฺขเว โกฏฺฐโก สมฺมชฺชิตพฺโพ สเจ อุปชฺฌายสาลา อุกฺกาปิตา ภิกฺขเว อุปชฺฌายสาลา สมฺมชฺชิตพฺพา สเจ อคฺคิสาลา อุกฺกาปิตา ภิกฺขเว อคฺคิสาลา สมฺมชฺชิตพฺพา สเจ วจฺจกุฏี อุกฺกาปิตา ภิกฺขเว วจฺจกุฏี สมฺมชฺชิตพฺพา สเจ ปานียํ น โหติ ปานียํ อุปฏฺฐาเปตพฺพํ สเจ ปริโภชนียํ น โหติ ปริโภชนียํ อุปฏฺฐาเปตพฺพํ สเจ อาจมนกุมฺภิยา อุทกํ น โหติ อาจมนกุมฺภิยา อุทกํ อาสิญฺจิตพฺพํ ฯ สเจ สทฺธิวิหาริกสฺส อนภิรตี อุปฺปชฺชติ โหติ อุปชฺฌายเน รูปกามสาเตปิ รูปกามสาปิเตปิ ธมฺมกถา วตฺตพฺพา สเจ สทฺธิวิหาริกสฺส กุกฺกุจฺจํ อุปฺปชฺชติ โหติ อุปชฺฌายเน วิโนเทตพฺพํ วิโนทาปิเตปิ ธมฺมกถา วตฺตพฺพา สเจ สทฺธิวิหาริกสฺส ทิฏฺฐิคตี อุปฺปชฺชติ โหติ

កឋិនវេលាថ្ងៃ ត្រូវបិទបង្ខិចកឋិនវេលាយប់ បើរដូវក្តៅ ឧបដ្ឋាយ៍ត្រូវបិទបង្ខិចកឋិនវេលាថ្ងៃ ត្រូវបើកបង្ខិចកឋិនវេលាយប់វិញ ។ បើទីបរិវេណស្មោកគ្រោកមិនស្អាត ឧបដ្ឋាយ៍ត្រូវបោសបរិវេណចេញ បើបន្ទប់ស្មោកគ្រោកមិនស្អាត ត្រូវបោសបន្ទប់ចេញ បើពេងសម្រាប់ធាន់មិនស្អាត ត្រូវបោសពេងសម្រាប់ធាន់ចេញ បើពេងក្តើនស្មោកគ្រោក ត្រូវបោសពេងក្តើនចេញ បើបង្គន់ស្មោកគ្រោក ត្រូវបោសសំអាតបង្គន់ បើគ្មានទឹកសម្រាប់ធាន់ ត្រូវដំកល់ទឹកសម្រាប់ធាន់ បើគ្មានទឹកសម្រាប់ប្រើប្រាស់ ត្រូវដំកល់ទឹកសម្រាប់ប្រើប្រាស់ បើទឹកកឋិនក្អមសម្រាប់លាងអាចមន៍គ្មានទេ ត្រូវចាក់ទឹកទៅកឋិនក្អមសម្រាប់លាងអាចមន៍ ។ បើសទ្ធិវិហារិកមានសេចក្តីអផ្សុក ឧបដ្ឋាយ៍ត្រូវទាំចៀសចេញទៅកំសាន្តដោយខ្លួនឯង ឬប្រើគេឲ្យទាំចៀសចេញទៅកំសាន្តក៏បាន ឬត្រូវធ្វើធម្មកថាដល់សទ្ធិវិហារិកនោះ បើសទ្ធិវិហារិកមានសេចក្តីសង្ស័យកើតឡើង ឧបដ្ឋាយ៍ត្រូវបន្ទោបង់ដោយខ្លួនឯង ឬរកគេឲ្យជួយបន្ទោបង់ក៏បាន ឬត្រូវធ្វើធម្មកថាដល់សទ្ធិវិហារិកនោះ បើសេចក្តីយល់ខុសកើតឡើងដល់សទ្ធិវិហារិក ឧបដ្ឋាយ៍ត្រូវដោះ

ឧបដ្ឋាយេន ភិក្ខវេ តុម្ភេ ភិក្ខវោ វេ តុម្ភេ ឧបដ្ឋាតព្ពា ។ សេយ្យថាបិ ភិក្ខវេ សង្ឃវិហារវិភោ ភវិតុកាមេ អដ្ឋាបនេ ហោតិ អវិភត្តសារេ ហោ ឧបដ្ឋាយេន ឧស្សុក្កំ តាតព្ពំ ភវិស្សតិ ខោ សង្ឃោ សង្ឃវិហារវិភត្តសារេ បរិភោគំ ឧទេយ្យាតិ សចេ សង្ឃវិហារវិភោ អូលាយ បដិភស្សារេ ហោតិ ឧបដ្ឋាយេន ឧស្សុក្កំ តាតព្ពំ ភវិស្សតិ ខោ សង្ឃោ សង្ឃវិហារំ អូលាយ បដិភសេស្សយ្យាតិ សចេ សង្ឃវិហារវិភោ មានត្តារេ ហោតិ ឧបដ្ឋាយេន ឧស្សុក្កំ តាតព្ពំ ភវិស្សតិ ខោ សង្ឃោ សង្ឃវិហារំ ភស្សុ មានត្តំ ឧទេយ្យាតិ សចេ សង្ឃវិហារវិភោ អព្ភានារេ ហោតិ ឧបដ្ឋាយេន ឧស្សុក្កំ តាតព្ពំ ភវិស្សតិ ខោ សង្ឃោ សង្ឃវិហារំ អព្ភេយ្យាតិ ។ សចេ សង្ឃោ សង្ឃវិហារវិភត្តសារេ ភេទ្ទុំ ភេត្តុកាមោ ហោតិ ឥត្ថន្និយំ វា និយស្សុំ វា បព្ភាជនីយំ វា បដិសារណីយំ វា ឧក្ខេបនីយំ វា ឧបដ្ឋាយេន ឧស្សុក្កំ តាតព្ពំ ភវិស្សតិ ខោ សង្ឃោ សង្ឃវិហារវិភត្តសារេ ភេទ្ទុំ ន ភវេយ្យ លហុភាយ វា បរិណាមេយ្យាតិ ភេទំ វា បនស្សេ

ស្រាយ (ពន្យល់) ដោយខ្លួនឯង ឬប្រើគេឲ្យជួយដោះស្រាយ (ពន្យល់ឲ្យ
លះទិដ្ឋិនោះចេញ) ក៏បាន ឬត្រូវធ្វើធម្មកថាដល់សទ្ធិវិហារិកនោះ ។ បើ
សទ្ធិវិហារិកត្រូវគុក្កាបត្តិគួរនឹងចូលបវារណាស ឧបជ្ឈាយ៍ត្រូវធ្វើសេចក្តីរួល់
ខ្លួយថា សង្ឃគួរឲ្យបវារណាដល់សទ្ធិវិហារិកដោយឧបាយដូចម្តេចហ្ន៎ បើ
សទ្ធិវិហារិកគួរដល់កិរិយាឲ្យអន្តរាបត្តិមកជាក់កង់មូលាបត្តិ ឧបជ្ឈាយ៍
ត្រូវធ្វើសេចក្តីរួល់ខ្លួយថា សង្ឃគប្បីឲ្យអន្តរាបត្តិមកជាក់កង់មូលាបត្តិ
ចំពោះសទ្ធិវិហារិកដោយឧបាយដូចម្តេចហ្ន៎ បើសទ្ធិវិហារិកគួរដល់មានត្ត
ឧបជ្ឈាយ៍ត្រូវធ្វើសេចក្តីរួល់ខ្លួយថា សង្ឃគប្បីឲ្យមានត្តដល់សទ្ធិវិហារិក
ដោយឧបាយដូចម្តេចហ្ន៎ បើសទ្ធិវិហារិកគួរដល់អព្ភានកម្ម ឧបជ្ឈាយ៍ត្រូវ
ធ្វើសេចក្តីរួល់ខ្លួយថា សង្ឃគប្បីធ្វើអព្ភានកម្មចំពោះសទ្ធិវិហារិកដោយ
ឧបាយដូចម្តេចហ្ន៎ ។ បើសង្ឃចង់ធ្វើកម្មគឺ តជ្ជនីយកម្ម នីយស្សកម្ម
បព្វាជនីយកម្ម បដិសារណីយកម្ម ឧក្ខេបនីយកម្ម ដល់សទ្ធិវិហា-
រិក ឧបជ្ឈាយ៍ត្រូវធ្វើសេចក្តីរួល់ខ្លួយថា សង្ឃកុំគប្បីធ្វើកម្មឬគប្បីបង្អោន
ទៅដើម្បីកម្មស្រាលដល់សទ្ធិវិហារិកដោយឧបាយដូចម្តេចហ្ន៎ បើជាកម្មគឺ

ហោតិ សង្ឃេន កម្មំ តជ្ជនីយំ វា និយស្សំ វា បព្ពា-
ជនីយំ វា បដិសារណីយំ វា ឧក្ខេបនីយំ វា ឧបជ្ឈា-
យេន ឧស្សុក្កំ កាតព្ពំ កិន្តិ នុ ខោ សទ្ធិវិហារិកោ
សម្មាវត្តេយ្យ លោមំ ចាតេយ្យ នេត្ថារំ វត្តេយ្យ សង្ឃេ
តំ កម្មំ បដិប្បស្សម្ភេយ្យាតិ ។ សចេ សទ្ធិវិហារិកស្ស
ចីវរំ ឆោវិតព្ពំ ហោតិ ឧបជ្ឈាយេន អាចិក្ខិតព្ពំ ឱវរ
ឆោវេយ្យាសីតិ ឧស្សុក្កំ វា កាតព្ពំ កិន្តិ នុ ខោ
សទ្ធិវិហារិកស្ស ចីវរំ ឆោវិយេថាតិ សចេ សទ្ធិវិហារិ-
កស្ស ចីវរំ កាតព្ពំ ហោតិ ឧបជ្ឈាយេន អាចិក្ខិតព្ពំ
ឱវរ កវេយ្យាសីតិ ឧស្សុក្កំ វា កាតព្ពំ កិន្តិ នុ ខោ
សទ្ធិវិហារិកស្ស ចីវរំ កវិយេថាតិ សចេ សទ្ធិវិហារិ-
កស្ស រជនំ បចិតព្ពំ ហោតិ ឧបជ្ឈាយេន អាចិក្ខិ-
តព្ពំ ឱវរ បចេយ្យាសីតិ ឧស្សុក្កំ វា កាតព្ពំ កិន្តិ
នុ ខោ សទ្ធិវិហារិកស្ស រជនំ បចិយេថាតិ សចេ
សទ្ធិវិហារិកស្ស ចីវរំ រជេតព្ពំ ហោតិ ឧបជ្ឈាយេន
អាចិក្ខិតព្ពំ ឱវរ រជេយ្យាសីតិ ឧស្សុក្កំ វា កាតព្ពំ កិន្តិ

តជ្ជនីយកម្មក្តី និយស្សកម្មក្តី បព្ពាជនីយកម្មក្តី បដិសារណីយកម្មក្តី
ឧក្ខេបនីយកម្មក្តី សង្ឃធ្វើដល់សទ្ធិវិហារិកនោះរួចទៅហើយ
ឧបជ្ឈាយ៍ត្រូវធ្វើសេចក្តីឲ្យល់ឮថា ធ្វើដូចម្តេចហ្ន៎ សទ្ធិវិហារិកគប្បី
ប្រតិបត្តិដោយប្រពៃគប្បីសម្របភេម (កុំប្រកែកប្រកាន់) គប្បីប្រតិបត្តិវត្ត
គួរកន្លងការរើខ្លួនចេញអំពីអាបត្តិ សង្ឃគប្បីរម្ងាប់ទុវត្តមនោះ ។ បើចីវរ
របស់សទ្ធិវិហារិកគួរនឹងលាង ឧបជ្ឈាយ៍ត្រូវប្រាប់ថា អ្នកឯងគប្បីលាង
យ៉ាងនេះ ឬគប្បីធ្វើសេចក្តីឲ្យល់ឮថា ចីវរបស់សទ្ធិវិហារិកគួរនឹង
លាងដូចម្តេចហ្ន៎ បើចីវរបស់សទ្ធិវិហារិកគួរនឹងធ្វើ (មានជេរប៉ះជាដើម)
ឧបជ្ឈាយ៍ត្រូវប្រាប់ថា អ្នកគប្បីធ្វើយ៉ាងនេះ ឬត្រូវធ្វើសេចក្តីឲ្យល់ឮថា
ចីវរបស់សទ្ធិវិហារិកគួរនឹងធ្វើដោយឧបាយដូចម្តេចហ្ន៎ បើគ្រឿងជ្រលក់
របស់សទ្ធិវិហារិកគួរនឹងចំអិន ឧបជ្ឈាយ៍ត្រូវប្រាប់ថា អ្នកឯងត្រូវចំអិន
គ្រឿងជ្រលក់យ៉ាងនេះ ឬត្រូវធ្វើសេចក្តីឲ្យល់ឮថា គ្រឿងជ្រលក់
របស់សទ្ធិវិហារិកគួរនឹងចំអិនដោយឧបាយដូចម្តេចហ្ន៎ បើចីវរបស់សទ្ធិវិ-
ហារិកគួរនឹងជ្រលក់ ឧបជ្ឈាយ៍ត្រូវប្រាប់ថា អ្នកគប្បីជ្រលក់ចីវរបែបនេះ
ឬត្រូវធ្វើសេចក្តីឲ្យល់ឮថា ចីវរបស់សទ្ធិវិហារិកគួរនឹងជ្រលក់ដោយ

ฌ ขา สทฺธิวิหาริกสฺส จีวรํ ปฏิเยฺยกาตพฺพ จีวรํ ปฏิคฺคเหตพฺพ สาฏกกํ สมฺปฏิจฺฉกกํ สมฺปฏิจฺฉกกรณตฺถาย ฌ ๓ อฏฺฐนฺน ปเรว ปจฺจาสีสิตพฺพ ฯ สเจ สทฺธิวิหาริกา ตีณาเน ปโหติ ยาวตีหกาลปรมตา ปฏิคฺคเหตพฺพ อาหเรตพฺพนฺติ ฯ

สทฺธิวิหาริกวตฺตกถา นิฏฺฐิตา ฯ

(๘๓) เตน ขา ปน สมเยน สทฺธิวิหาริกา อุปชฺฌายเสฺส ฌ สมฺมาวตฺตนฺติ ฯ เย เต ภิกฺขู อปฺปิจฺฉา ฯเป ฯ เต อุชฺฌายนฺติ ขียนฺติ วิปาเจนฺติ กถ ปน นาม สทฺธิวิหาริกา อุปชฺฌายเสฺส ฌ สมฺมาวตฺติสฺสนฺตีติ ฯ อถ ขา เต ภิกฺขู ภควโต ปฏิเวเทสุ ฯ สจฺจ กิร ภิกฺขเว สทฺธิวิหาริกา อุปชฺฌายเสฺส ฌ สมฺมาวตฺตนฺตีติ ฯ สจฺจ ภควาติ ฯ วิครหิ พุทฺโธ ภควา กถ หิ นาม ภิกฺขเว สทฺธิวิหาริกา อุปชฺฌายเสฺส ฌ สมฺมาวตฺติสฺสนฺตีติ ฯ วิครหิตฺวา ธมฺมึ กถ กตฺวา ภิกฺขู อามนฺเตสิ ฌ ภิกฺขเว สทฺธิวิหาริเกน ฌ

ឧបាយដូចម្តេចហ្ន៎ កាលបើជ្រលក់ចីវរត្រូវជ្រលក់ដោយបៃតងឲ្យសព្វស្មើល្អ ប្រសិនបើដំណក់ទឹកស្រស់មិនទាន់អស់ ឧបជ្ឈាយ៍កុំអាលដើរចេញ ។ បើសទ្ធិវិហារិកមានជម្ងឺ ឧបជ្ឈាយ៍ត្រូវថែទាំអស់មួយជីវិត ត្រូវរង់ចាំលុះតែជាជម្ងឺ ។

ឯបំ សទ្ធិវិហារិកវត្តំ ។

(៨៣) សម័យនោះឯង ពួកសទ្ធិវិហារិកមិនបានប្រព្រឹត្តល្អ (គឺមិនបានយកចិត្តទុកដាក់) នឹងឧបជ្ឈាយ៍ទាំងឡាយឡើយ ។ កិក្ខុទាំងឡាយណាមានសេចក្តីជ្រាថ្នាតិច ។ បេ ។ កិក្ខុទាំងនោះពោលទោសតិះដៀល បន្ទុះបង្អាប់ថា ពួកសទ្ធិវិហារិកមិនសមបើនឹងមិនប្រព្រឹត្តល្អនឹងឧបជ្ឈាយ៍សោះ ។ គ្រានោះ កិក្ខុទាំងនោះបានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរថា ម្នាលកិក្ខុទាំងឡាយ ឮថា ពួកសទ្ធិវិហារិកមិនបានប្រព្រឹត្តល្អនឹងឧបជ្ឈាយ៍ពិតមែនឬ ។ កិក្ខុទាំងឡាយក្រាបទូលថា សូមទ្រង់ព្រះមេត្តាជ្រាបសពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលកិក្ខុទាំងឡាយ ពួកសទ្ធិវិហារិកមិនសមបើនឹងមិនប្រព្រឹត្តល្អនឹងឧបជ្ឈាយ៍ទេ ។ ព្រះដ៏មានបុណ្យទ្រង់បន្ទោសហើយទ្រង់ធ្វើធម្មីកថា រួចត្រាស់ហៅកិក្ខុទាំងឡាយ

อุปชฺฌายมฺหิ ฯ สมฺมาวตฺตึ ตฺวํ ยาว ฯ สมฺมาวตฺตเยยฺย อาจริยมฺหิ นิกฺกุชฺชสฺสาติ ฯ เอวं[๑] สมฺมาวตฺตนฺติ ฯ ภควาโต ฯเปฯ อาโรเจสุ ฯ อนุชานามิ ภิกฺขเว อสมฺมาวตฺตนฺตํ ปณาเมตุ ฯ ฯเปฯ ภิกฺขเว ปณาเมตพฺพา ปณาเมตพฺพา ปณาเมมิ ตนฺติ ฯ มายิฯ ปฏิกฺกมิตพฺพา ฯ ฉิยาว เต ปตฺตจีวรนฺติ ฯ ฯเปฯ อุปชฺฌาตพฺพาติ ฯ กายเกน วิญฺญาเปตพฺพา ฯ วาจาย วิญฺญาเปตพฺพา กายเกน ฯ วาจาย วิญฺญาเปตพฺพา ปณาเมมิ โตติ เปเสติ สทฺธิวิหาริโกปิ ฯ กายเกน วิญฺญาเปตพฺพา ฯ วาจาย วิญฺญาเปตพฺพา ฯ กายเกน ฯ วาจาย วิญฺญาเปตพฺพา ฯ ปณาเมมิ โตติ **เปเสติ** สทฺธิวิหาริโกปิ ฯ เตน ขฺวา ปน สมเยน สทฺธิวิหาริกา ปณาเมตา ฯ ขมาเปนฺติ ฯ ภควาโต ฯเปฯ อาโรเจสุ ฯ อนุชานามิ ภิกฺขเว ขมาเปตุนฺติ ฯ

---

๑ เก เอวเ สมฺมาวตฺตนฺตีติปิ ฉาหิ ทิสฺสติ ฯ

មកទ្រង់បញ្ជាត្តថា ម្នាលភិក្ខុទាំងឡាយ សង្ឃវិហារកម្មមិនគួរនឹងមិនប្រព្រឹត្តល្អនឹងឧបជ្ឈាយ៍ទេ ភិក្ខុណាដែលមិនប្រព្រឹត្តល្អនឹងឧបជ្ឈាយ៍ ត្រូវអាបត្តិទុក្កដ ។ ពួកសង្ឃវិហារកទាំងនោះក៏នៅតែមិនប្រព្រឹត្តល្អក្នុងឧបជ្ឈាយ៍ដដែល ។ ភិក្ខុទាំងឡាយបានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ទើបព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យឧបជ្ឈាយ៍បណ្តេញសង្ឃវិហារក ដែលមិនបានប្រព្រឹត្តល្អបេញ ។ ម្នាលភិក្ខុទាំងឡាយ ឧបជ្ឈាយ៍ត្រូវបណ្តេញសង្ឃវិហារកយ៉ាងនេះ គឺឧបជ្ឈាយ៍បញ្ជាក់ឲ្យដឹងដោយកាយ បញ្ជាក់ឲ្យដឹងដោយវាចាឬទាំងកាយទាំងវាចាថា អញបណ្តេញអ្នកឯងឥឡូវនេះក្តី ថាអ្នកឯងកុំចូលមកកាន់ទីនេះក្តី ថាអ្នកឯងចូរនាំយកចាត្រនឹងចីវរបស់អ្នកទៅក្តី ខ្លួនអញអ្នកឯងមិនត្រូវមកបម្រើទេក្តី (យ៉ាងនេះហៅថា) ឧបជ្ឈាយ៍បណ្តេញសង្ឃវិហារក (បើ) ឧបជ្ឈាយ៍មិនបានបញ្ជាក់ឲ្យដឹងដោយកាយ ឬដោយវាចា ឬទាំងកាយទាំងវាចា (យ៉ាងនេះហៅថា) ឧបជ្ឈាយ៍មិនបានបណ្តេញសង្ឃវិហារកទេ ។ សម័យនោះ ពួកសង្ឃវិហារកដែលឧបជ្ឈាយ៍បានបណ្តេញចេញហើយក៏មិនបានឲ្យឧបជ្ឈាយ៍អត់ទោសឲ្យវិញ ។ ភិក្ខុទាំងឡាយបានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យ

នេវ ខោ បនាហំ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន កិត្តាវ បណាមិតេន ន ខោ បនាហំ ។ ខមាបេតព្ពោ យោ ន ខមាបេយ្យ អាបត្តិំ ទុក្កដស្សាតិ ។ តេន ខោ បន សមយេន ឧបដ្ឋាយា ខមាបិយមានា ន ខមន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ខមិតុន្តិ ។ នេវ ខមន្តិ ។ សង្ឃិវិហារកា បក្កមន្តិបិ វិព្ភមន្តិបិ តិត្ថិយេសុបិ សង្កមន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ ន កិត្តាវ ខមាបិយមានេន ន ខមិតព្ពំ យោ ន ខមេយ្យ អាបត្តិ ទុក្កដស្សាតិ ។

ពួកសទ្ធិវិហារិកសូមឲ្យឧបជ្ឈាយ៍អត់ទោសឲ្យបាន ។ ពួកសទ្ធិវិហារិកនៅតែមិនបានសូមឲ្យឧបជ្ឈាយ៍អត់ទោសឲ្យទៀ ។ ភិក្ខុទាំងឡាយបានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ សទ្ធិវិហារិកដែលឧបជ្ឈាយ៍បណ្តេញចេញទៅហើយ មិនគួរនឹងមិនសូមឲ្យឧបជ្ឈាយ៍អត់ទោសឲ្យទេ សទ្ធិវិហារិកណាមួយមិនបានសូមឲ្យឧបជ្ឈាយ៍អត់ទោសឲ្យ ត្រូវអាបត្តិទុក្កដ ។ ក្នុងសម័យនោះឯង ពួកឧបជ្ឈាយ៍ កាលបើសទ្ធិវិហារិកទៅសូមខមាទោសវិញ ក៏មិនព្រមអត់ទោសឲ្យទៀ ។ ភិក្ខុទាំងឡាយបានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យឧបជ្ឈាយ៍អត់ទោសដល់សទ្ធិវិហារិក ។ ឧបជ្ឈាយ៍ទាំងនោះក៏មិនព្រមអត់ទោសឲ្យទៀ ។ ឯពួកសទ្ធិវិហារិករត់ចេញទៅខ្លះ សឹកចេញទៅខ្លះ រត់ចូលពួកតិរ្ថិយខ្លះ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់បញ្ញត្តថា ម្នាលភិក្ខុទាំងឡាយ កាលបើសទ្ធិវិហារិក មកសូមខមាទោស ឧបជ្ឈាយ៍ត្រូវតែអត់ទោសឲ្យ (បើ) ឧបជ្ឈាយ៍ណាមួយមិនអត់ទោសឲ្យទេ ត្រូវអាបត្តិទុក្កដ ។

[๘๔] តេន ខោ បន សមយេន ឧបដ្ឋាយោ សម្ពា-
ឝ្ឝនំ បណ្ណាមេន្តំ អសម្ពាឝ្ឝនំ ន បណ្ណាមេន្តិ ។ ភគ-
វតោ ឯតមត្ថំ អារោចេសុំ ។ ន តិត្ថេ សម្ពាឝ្ឝនោ ប-
ណ្ណាមេតព្ពោ យោ បណ្ណាមេយ្យ អាបត្តិ ទុក្កដស្ស ន ច
តិត្ថេ អសម្ពាឝ្ឝនោ ន បណ្ណាមេតព្ពោ យោ ន បណ្ណា-
មេយ្យ អាបត្តិ ទុក្កដស្ស ។ បញ្ចហិ តិត្ថេ អង្គេហិ
សមន្នាគតោ សន្ទិដ្ឋិហារិកោ បណ្ណាមេតព្ពោ ឧបដ្ឋា-
យម្ហិ ឆាឯមត្តំ បេមំ ហោតិ ឆាឯមត្តោ បសាទោ ហោតិ
ឆាឯមត្តា ហិរី ហោតិ ឆាឯមត្តោ តាវភោ ហោតិ ឆាឯ-
មត្តា ភាវនា ហោតិ ឥមេហិ ខោ តិត្ថេ បញ្ចហង្គេហិ
សមន្នាគតោ សន្ទិដ្ឋិហារិកោ បណ្ណាមេតព្ពោ ។ បញ្ចហិ
តិត្ថេ អង្គេហិ សមន្នាគតោ សន្ទិដ្ឋិហារិកោ ន បណ្ណា-
មេតព្ពោ ឧបដ្ឋាយម្ហិ អឯមត្តំ បេមំ ហោតិ អឯមត្តោ

[៨៤] សម័យនោះឯង ពួកឧបដ្ឋាយ៍បណ្តេញសទ្ធិវិហារិកដែលប្រព្រឹត្តល្អចេញ មិនបានបណ្តេញសទ្ធិវិហារិកដែលប្រព្រឹត្តអាក្រក់ចេញឡើយ ។ កិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ចញ្ចតថា ម្នាលភិក្ខុទាំងឡាយ សទ្ធិវិហារិកដែលប្រព្រឹត្តល្អហើយ ឧបដ្ឋាយ៍មិនត្រូវបណ្តេញចេញទេ (បើ) ឧបដ្ឋាយ៍ណាមួយបណ្តេញចេញ ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ ចំណែកខាងសទ្ធិវិហារិកដែលប្រព្រឹត្តអាក្រក់ ឧបដ្ឋាយ៍ត្រូវតែបណ្តេញចេញចាន (បើ) ឧបដ្ឋាយ៍ណាមួយមិនបណ្តេញចេញទេ ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ សទ្ធិវិហារិកដែលប្រកបដោយអង្គ ៥ ឧបដ្ឋាយ៍ត្រូវតែបណ្តេញចេញចាន (ឯអង្គ ៥ នោះ) គឺសទ្ធិវិហារិកមិនបានស្រឡាញ់ឧបដ្ឋាយ៍ដោយពិត ១ មិនមានសេចក្តីជ្រះថ្លាដោយពិត ១ មិនមានសេចក្តីអៀនខ្មាសដោយពិត ១ មិនមានសេចក្តីគោរពដោយពិត ១ មិនមានការចំរើនការនាដោយពិត ១ ម្នាលភិក្ខុទាំងឡាយ សទ្ធិវិហារិកប្រកបដោយអង្គ ៥ នេះឯងហើយ ឧបដ្ឋាយ៍ត្រូវតែបណ្តេញចេញ ។ ម្នាលភិក្ខុទាំងឡាយ សទ្ធិវិហារិកដែលប្រកបដោយអង្គ ៥ (នោះ) ឧបដ្ឋាយ៍មិនត្រូវបណ្តេញចេញទេ (ឯអង្គ ៥ នោះ) គឺសទ្ធិវិហារិកមានសេចក្តីស្រឡាញ់ឧបដ្ឋាយ៍ដោយពិត ១ មានសេចក្តីជ្រះថ្លាដោយ

ปสาเทา เหาติ อธิมตฺตา หิรี เหาติ อธิมตฺตา การเว เหาติ อธิมตฺตา การณา เหาติ สเมหิ เหา กิกฺเวา ปญฺ-หาเฉหิ สมฺปาทกเตา สทฺธิวิหาริเกา ณ ปณามเม-ตเพฺพ ฯ ปญฺหิ กิกฺเวา อาเฉหิ สมฺปาทกเตา สทฺธิวิหาริ-เกา อลำ ปณามเมตุ๋ อุปชฺฌายมฺหิ ชาธิมตฺตำ เปมำ เหา-ติ ชาธิมตฺตา ปสาเทา เหาติ ชาธิมตฺตา หิรี เหาติ ชาธิมตฺตา การเว เหาติ ชาธิมตฺตา การณา เหาติ ส-เมหิ เหา กิกฺเวา ปญฺหาเฉหิ สมฺปาทกเตา สทฺธิวิ-หาริเกา อลำ ปณามเมตุ๋ ฯ ปญฺหิ กิกฺเวา อาเฉหิ สมฺปาทกเตา สทฺธิวิหาริเกา ชาลำ ปณามเมตุ๋ อุปชฺฌา-ยมฺหิ อธิมตฺตำ เปมำ เหาติ อธิมตฺตา ปสาเทา เหาติ อธิมตฺตา หิรี เหาติ อธิมตฺตา การเว เหาติ อธิมตฺตา การณา เหาติ สเมหิ เหา กิกฺเวา ปญฺหาเฉหิ สมฺปาทก-เตา สทฺธิวิหาริเกา ชาลำ ปณามเมตุ๋ ฯ ปญฺหิ กิกฺเวา อาเฉหิ สมฺปาทกำ สทฺธิวิหาริกำ อปฺปณา-เมตฺวา อุปชฺฌายา สาคิสาเร เหาติ ปณามเมตฺวา

ពិត ១ មានសេចក្តីអៀនខ្មាសៈដោយពិត ១ មានសេចក្តីគោរពដោយពិត ១ មានការចំរើនការនាដោយពិត ១ ម្នាលកិកុគាំង ឆ្ងាយ សន្ធវិបាកវិតក្កប្រកបដោយអង្គ ៥ នេះឯងហើយ ឧបជ្ឈាយ៍មិនត្រូវបណ្តោញចេញទេ ។ ម្នាលកិកុគាំង ឆ្ងាយ សន្ធវិបាកវិតក្កប្រកបដោយអង្គ ៥ គួរឲ្យឧបជ្ឈាយ៍បណ្តោញចេញ (ឯអង្គ ៥ នោះ) គឺសន្ធវិបាកវិតក្កគ្មានសេចក្តីស្រឡាញ់ឧបជ្ឈាយ៍ដោយពិត ១ គ្មានសេចក្តីជ្រះថ្លាដោយពិត ១ គ្មានសេចក្តីអៀនខ្មាសដោយពិត ១ គ្មានសេចក្តីគោរពដោយពិត ១ គ្មានការចំរើនការនាដោយពិត ១ ម្នាលកិកុគាំង ឆ្ងាយ សន្ធវិបាកវិតក្កប្រកបដោយអង្គគាំង ៥ នេះ គួរឲ្យឧបជ្ឈាយ៍បណ្តោញចេញ ។ ម្នាលកិកុគាំង ឆ្ងាយ សន្ធវិបាកវិតក្កប្រកបដោយអង្គ ៥ ឧបជ្ឈាយ៍មិនគួរបណ្តោញចេញទៀតឡើយ (ឯអង្គ ៥ នោះ) គឺសន្ធវិបាកវិតក្កមានសេចក្តីស្រឡាញ់ឧបជ្ឈាយ៍ដោយពិត ១ មានសេចក្តីជ្រះថ្លាដោយពិត ១ មានសេចក្តីអៀនខ្មាសដោយពិត ១ មានសេចក្តីគោរពដោយពិត ១ មានការចំរើនការនាដោយពិត ១ ម្នាលកិកុគាំង ឆ្ងាយ សន្ធវិបាកវិតក្កប្រកបដោយអង្គគាំង ៥ នេះ ឧបជ្ឈាយ៍មិនគួរបណ្តោញចេញទេ ។ ម្នាលកិកុគាំង ឆ្ងាយ ឧបជ្ឈាយ៍កាលមិនបណ្តោញសន្ធវិបាកវិតក្កដែលប្រកបដោយអង្គ ៥ (ចំណែកខាង ១ ស) ចេញទេ នឹងមានទោស (គឺត្រូវអាបត្តិមិនខាន) លើឧបជ្ឈាយ៍

อนติสาเร โหติ อุปฑฺฒายปฺหิ ฉายมฺปิ ปมาณมฺปิ โหติ ฉายมฺปิ ปมาโณปิ โหติ ฉายมฺปิ หิรีปิ โหติ ฉายมฺปิ ภารเกปิ โหติ ฉายมฺปิ ภาวนาปิ โหติ สเมหิ โข ภิกฺขเว ปญฺหาเฉหิ สมนฺนาคตสฺส สทฺธิวิหาริกสฺส อปฺปฏิกมฺเมน อุปฑฺฒายโน สาติสาเร โหติ ปฏิกมฺเมน อนติสาเร โหติ ฯ ปญฺหาหิ ภิกฺขเว เฉหิ สมนฺนาคตสฺส สทฺธิวิหาริกสฺส ปฏิกมฺเมน อุปฑฺฒายโน สาติสาเร โหติ อปฺปฏิกมฺเมน อนติสาเร โหติ อุปฑฺฒายปฺหิ อฉายมฺปิ โหติ อปมาณมฺปิ โหติ อปมาโณปิ โหติ อหิรีปิ โหติ อภารเกปิ โหติ อภาวนาปิ โหติ สเมหิ โข ภิกฺขเว ปญฺหาเฉหิ สมนฺนาคตสฺส สทฺธิวิหาริกสฺส ปฏิกมฺเมน อุปฑฺฒายโน สาติสาเร โหติ อปฺปฏิกมฺเมน อนติสาเร โหติ ฯ

បណ្តេញសទ្ធិវិហារិកដែលប្រកបដោយអង្គ ៥ នេះចេញ មិនមានទោសទេ (ឯអង្គ ៥នោះ) គឺសទ្ធិវិហារិកគ្មានសេចក្តីស្រឡាញ់ឧបជ្ឈាយ៍ដោយពិត ១ គ្មានសេចក្តីដែះថ្លាដោយពិត ១ គ្មានសេចក្តីអៀនខ្មាសដោយពិត ១ គ្មានសេចក្តីគោរពដោយពិត ១ គ្មានការចំរើនភាវនា ដោយពិត ១ ម្នាលភិក្ខុទាំងឡាយ ឧបជ្ឈាយ៍មិនបណ្តេញសទ្ធិវិហារិកដែលប្រកបដោយអង្គ ៥នេះឯង នឹងមានទោស (បើ) ឧបជ្ឈាយ៍បានបណ្តេញសទ្ធិវិហារិកដែលប្រកបដោយអង្គ ៥នេះឯង ក៏មិនមានទោសទេ ។ ម្នាលភិក្ខុទាំងឡាយ ឧបជ្ឈាយ៍បណ្តេញសទ្ធិវិហារិក ដែលប្រកបដោយអង្គទាំង ៥ (ចំណែកខាងត្រូវ) នឹងមានទោសមិនខាន (បើ) ឧបជ្ឈាយ៍មិនបានបណ្តេញសទ្ធិវិហារិកដែលប្រកបដោយអង្គ ៥នេះចេញទេ មិនមានទោសទេ (អង្គ ៥នោះ) គឺសទ្ធិវិហារិកមានសេចក្តីស្រឡាញ់ឧបជ្ឈាយ៍ដោយពិត ១ មានសេចក្តីដែះថ្លាដោយពិត ១ មានសេចក្តីអៀនខ្មាសដោយពិត ១ មានសេចក្តីគោរពដោយពិត ១ មានការចំរើនភាវនា ដោយពិត ១ ម្នាលភិក្ខុទាំងឡាយ ឧបជ្ឈាយ៍បណ្តេញសទ្ធិវិហារិកដែលប្រកបដោយអង្គទាំង ៥ នេះឯង នឹងមានទោសមិនខានទេ (បើ) ឧបជ្ឈាយ៍មិនបានបណ្តេញសទ្ធិវិហារិក ដែលប្រកបដោយអង្គទាំង ៥ នេះទេ មិនមានទោសទេ ។

(៨៥) តេន ខោ បន សមយេន អញ្ញតរោ ព្រាហ្មណោ[1] កិក្ខុ ឧបសង្កមិត្វា បព្ពជ្ជំ យាចិ ។ តំ កិក្ខូ ន ឥច្ឆិំសុ បព្ពាជេតុំ ។ សោ កិក្ខូសុ បព្ពជ្ជំ អលភមានោ កិសោ អហោសិ លូខោ ទុព្ពណ្ណោ ឧប្បណ្ឌុប្បណ្ឌុកជាតោ ជមនិសន្ថតគត្តោ ។ អទ្ទសា ខោ ភគវា តំ ព្រាហ្មណំ កិសំ លូខំ ទុព្ពណ្ណំ ឧប្បណ្ឌុប្បណ្ឌុកជាតំ ជមនិសន្ថតគត្តំ ឯស្ស ន កិក្ខូ អាមន្តេសិ កិន្នុ ខោ សោ កិក្ខវេ ព្រាហ្មណោ កិសោ លូខោ ទុព្ពណ្ណោ ឧប្បណ្ឌុប្បណ្ឌុកជាតោ ជមនិសន្ថតគត្តោតិ ។ ឯសោ ភន្តេ ព្រាហ្មណោ កិក្ខូ ឧបសង្កមិត្វា បព្ពជ្ជំ យាចិ តំ កិក្ខូ ន ឥច្ឆិំសុ បព្ពាជេតុំ សោ កិក្ខូសុ បព្ពជ្ជំ អលភមានោ កិសោ លូខោ ទុព្ពណ្ណោ ឧប្បណ្ឌុប្បណ្ឌុកជាតោ ជមនិសន្ថតគត្តោតិ ។ អថខោ ភគវា កិក្ខូ អាមន្តេសិ

---

១ អញ្ញតរោ រាជា នាម ព្រាហ្មណោតិ អម្ហាកំ យោគ្គេ ទិស្សតិ ។ តញ្ញេវ នាដកាយម្បិ តំ នាមំ បាកដំ ហោតិ ។ យស្មា បន អញ្ញតរសទ្ទេន អនិយមេ បតេ នាមំ វត្តព្ពំ ន ហោតិ នាមេ វា វុត្តេ អនិយមោ ឧត្តព្ពោ ន ហោតិ ឥស្មា រាជា នាមាតិ បាឋិទ្ធយំ អតិរេកត្តិំ ទដ្ឋព្ពំ ។ ឥតរថា អញ្ញតរសទ្ទោ ន ភវេយ្យ អទ្ទសា ខោ ភគវា រាធំ ព្រាហ្មណន្តិ ច វត្តព្ពំ ភវេយ្យ អយម្បន ឩ. ម. យោគ្គេ អនុវត្តិត្វា សោធិតោតិ វេទិតព្ពោ ។

[៨៩] សម័យនោះឯង មានព្រាហ្មណ៍ម្នាក់ចូលទៅរកពួកភិក្ខុ ហើយសូមផ្ទះ ។ ពួកភិក្ខុមិនជ្រាបច្បាស់ឯបំបួសព្រាហ្មណ៍នោះឡើយ ។ ព្រាហ្មណ៍នោះកាលបើមិនបានផ្ទះក្នុងសំណាក់ពួកភិក្ខុហើយ ក៏ទៅជាស្គាំងស្គមមានសម្បុរអាក្រក់ កើតរោគលឿងស្វិតស្វាំងលេចសរសៃសរសៃរោមនៅខ្លួន ។ ព្រះដ៏មានព្រះភាគទ្រង់ចាន់តេទៅឃើញព្រាហ្មណ៍នោះស្គាំងស្គមមានសម្បុរអាក្រក់ កើតរោគលឿងស្វិតស្វាំងលេចសរសៃសរសៃរោមនៅខ្លួន (ដូច្នោះ) លុះទ្រង់ទតឃើញហើយក៏ទ្រង់ត្រាស់ហៅពួកភិក្ខុមកសួរថា ម្នាលភិក្ខុទាំងឡាយ ឯព្រាហ្មណ៍នោះចាន់ជាស្គាំងស្គមមានសម្បុរអាក្រក់ កើតរោគលឿងស្វិតស្វាំងលេចសរសៃសរសៃរោមនៅខ្លួន តើដោយហេតុអ្វី ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់ព្រះមេត្តាជ្រាបចុះ ព្រាហ្មណ៍នុ៎ះបានចូលមករកពួកភិក្ខុហើយអង្វរសូមផ្ទះ ពួកភិក្ខុមិនជ្រាបច្បាស់ឯបំបួសព្រាហ្មណ៍នោះឡើយ ព្រាហ្មណ៍នោះកាលបើមិនបានផ្ទះក្នុងសំណាក់ពួកភិក្ខុហើយ ក៏ទៅជាស្គាំងស្គមមានសម្បុរអាក្រក់ កើតរោគលឿងស្វិតស្វាំងលេចសរសៃសរសៃរោមនៅខ្លួន ។ លំដាប់នោះឯង ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅពួកភិក្ខុមកត្រាស់សួរថា ម្នាលភិក្ខុ

โกจิ ปน เถโร กิญฺจาปิ ตสฺส พฺราหฺมณสฺส อธิการํ สรติ ฯ ฯลฯ ปุพฺเพ อายสฺมา สารีปุตฺโต กตาวกาโส ฯเปฯ อหมฺปิ เถโร กโรมิ ตสฺส พฺราหฺมณสฺส อธิการํ สรามีติ ฯ กึ ปน ตุมฺเห สารีปุตฺต ตสฺส พฺราหฺมณสฺส อธิการํ สรถาติ ฯ ๙๘ เมว กโรมิ โข พฺราหฺมณา ภูตปุพฺพํ พาราณสิยา จนฺทวตฺติยา นครทฺวารสมีเป ทฺวาทสโยชนิกา มหาวิปฺผารา อหิวาตโรคา อุปฺปชฺชิ ฯ สาปิ สารีปุตฺต กตญฺญู กตเวทิโน เถรา นาม ตุมฺเห สารีปุตฺต สปฺปุริสา กตาวิโน กตเวทิโน เถรา นาม ตุมฺเห สารีปุตฺต ตาทิสา พฺราหฺมณา ปญฺญาเปถ อุปสมฺปาเทถาติ ฯ กถญฺหิ นาม กโรมิ เถรา ตาทิสา พฺราหฺมณา ปญฺญาเปตพฺพา อุปสมฺปาเทตพฺพาติ ฯ อถ โข กตฺถ ปสฺสิ นิกฺขาเม ปสฺสิ ปกฺกมนฺโต ยตฺถ

តាំងឡាយ កិកុណាហ្មអាចរលឹកឃើញអធិការៈ(គុណ)របស់ព្រាហ្មណ៍នោះបាន ។ កាលបើព្រះអង្គទ្រង់សួរយ៉ាងនេះហើយ ព្រះសារីបុត្តដ៏មានអាយុក៏បានពោលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គ(អាច) រលឹកនូវអធិការៈ(គុណ) របស់ព្រាហ្មណ៍នោះបាន ។ ទ្រង់ត្រាស់សួរទៀតថា ម្នាលសារីបុត្ត អ្នកឯងរលឹកអធិការៈ(គុណ)របស់ព្រាហ្មណ៍នោះបានយ៉ាងដូចម្តេច ។ ព្រះសារីបុត្តទូលថា សូមទ្រង់ព្រះមេត្តាប្រោស កាលខ្ញុំព្រះអង្គទៅបិណ្ឌបាតក្នុងក្រុងពដគ្រឹះនេះ ព្រាហ្មណ៍នោះបានប្រើគេឲ្យប្រៃគេនចង្ហាន់មួយវែក សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គរលឹកបាននូវអធិការៈ(គុណ)របស់ព្រាហ្មណ៍នោះប៉ុណ្ណេះឯង ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា នែសារីបុត្ត ពាក្យដែលអ្នកពោលមកនេះប្រពៃណាស់ នែសារីបុត្ត ធម្មតាពួកសប្បុរសរមែងជាអ្នកកតញ្ញូកតវេទិ[1]ពិត ម្នាលសារីបុត្ត បើដូច្នោះចូរអ្នកឲ្យបព្វជ្ជានឹងឧបសម្បទាដល់ព្រាហ្មណ៍នោះ ។ ព្រះសារីបុត្តក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គនឹងត្រូវឲ្យបព្វជ្ជានឹងឧបសម្បទា ដល់ព្រាហ្មណ៍នោះដូចម្តេចទៅ ។ ព្រោះនិទាននេះដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើ

---

១ កតញ្ញូ ដោយអ្នកដឹងគុណដែលអ្នកដទៃបានធ្វើដល់ខ្លួន កតវេទី ដោយអ្នកប្រកាសនូវឧបការៈគុណដែលអ្នកដទៃធ្វើហើយប្រាកដ គឺតបគុណគេ ។

ตตฺถ กิญฺจิ อาทยนฺเต ยา สา กิญฺจิเว ยา ตัมหิ สมเย ตสฺมิญฺจ สมเย อนุญฺญาตา ตาหิ อนฺตมโส ปฏิกฺขิตฺตาหิปิ อนุชานิตาหิ กิญฺจิเว ฌานปฺปฏิลาเภน ตมฺเหน อุปสมฺปนฺนนฺติ[๑] เอวมฺปิ ปน กิญฺจิเว อุปสมฺปาเทตเพฺพ ฌานปฺปฏิลาเภน กิญฺจิกาย ปฏิลเยน สเทฺธา ญาเปตเพฺพ สุณาตุ เม ภนฺเต สเทฺธา อยํ ฬกฺขาโม ฬกฺขามสฺส อายสฺมโต อุปสมฺปทาเปกฺขา[๒] ฯ ยทิ สเทฺธสฺส ปตฺตกลฺลํ สเทฺธา ฬกฺขามํ อุปสมฺปาเทยฺย ฬกฺขามเมน อุปชฺฌายเตน ฯ เอสา ญตฺติ ฯ สุณาตุ เม ภนฺเต สเทฺธา อยํ ฬกฺขาโม ฬกฺขามสฺส อายสฺมโต อุปสมฺปทาเปกฺขา ฯ สเทฺธา ฬกฺขามํ อุปสมฺปาเทติ ฬกฺขามเมน อุปชฺฌายเตน ฯ ยสฺสายสฺมโต ขมติ ฬกฺขามสฺส อุปสมฺปทา ฬกฺขามเมน อุปชฺฌายเตน โส

---

๑ ม. อุปสมฺปาเทตุ ฯ ๒ อุปสมฺปาเปตีติปิ ปาโฐ ฯ

ន្ទូវដម្ដីកថាកងវេលានោះ រួចទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឧបសម្បទាណាដែលតថាគតបានអនុញ្ញាតដោយត្រៃសរណគមន៍រួចហើយ ចាប់ដើមពីថ្ងៃនេះទៅតថាគតឃាត់ន្ទូវឧបសម្បទានោះវិញ ម្នាលភិក្ខុទាំងឡាយ តទ្បូវតថាគតអនុញ្ញាតន្ទូវឧបសម្បទាដោយញត្តិចតុត្ថកម្ម គឺកម្មមានញត្តិជាគំរប់ ៤ វិញ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវឲ្យឧបសម្បទាបែបយ៉ាងនេះ ភិក្ខុអកត្វាសប្រតិពលត្រូវផ្តៀងសង្ឃថា បពិត្រព្រះគម្ដែងសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ដ្បិតឈ្មោះនេះជាឧបសម្បទាបេក្ខៈ[1] របស់លោកដ៏មានអាយុឈ្មោះនេះ។ បើកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីញុំាងឧបសម្បទាបេក្ខៈឈ្មោះនេះឲ្យបានឧបសម្បទា[2] ដោយមានព្រះថេរៈឈ្មោះនេះ ជាឧបជ្ឈាយ៍ចុះ។ ពាក្យនេះជាពាក្យផ្តៀងសង្ឃ (ឲ្យជ្រាប)។ បពិត្រព្រះគម្ដែងសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ (ដ្បិត) ឈ្មោះនេះជាឧបសម្បទាបេក្ខៈរបស់លោកដ៏មានអាយុឈ្មោះនេះ។ តទ្បូវសង្ឃញុំាងឈ្មោះនេះឲ្យបានឧបសម្បទាដោយមានព្រះថេរៈឈ្មោះនេះជាឧបជ្ឈាយ៍។ ឯការញុំាងឈ្មោះនេះឲ្យបានឧបសម្បទាដោយមានព្រះថេរៈឈ្មោះនេះជាឧបជ្ឈាយ៍ (បើ) គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀម

---

១ សាមណេរដែលត្រូវបួសជាភិក្ខុភាវៈ។ ២ ឲ្យដល់គូរគុណឧទ្ទេសាចារ្យខាងលើ គឺបានសម្រេចជាភិក្ខុភាវៈ។

ตุณฺหสฺส ยสฺส ขมติ โส กาเรยฺย ฯ ทุติ-
ยมฺปิ ฯเปฯ ตติยมฺปิ ฯเปฯ สุณาตุ เม ภนฺเต สงฺฆ
อยํ ฉนฺนาโม ฉนฺนามสฺส อายสฺมโต อุปสมฺป-
นาเปกฺโข ฯ สเจ สงฺฆ ฉนฺนามํ อุปสมฺปาเทติ ฉนฺนา
เมน อุปชฺฌาเยน ฯ ยสฺสายสฺมโต ขมติ ฉนฺนา-
มสฺส อุปสมฺปทา ฉนฺนาเมน อุปชฺฌาเยน โส ตุ-
ณฺหสฺส ยสฺส ขมติ โส กาเรยฺย ฯ ตติยมฺปิ
ฯเปฯ จตุตฺถมฺปิ ฯเปฯ สุณาตุ เม ภนฺเต สงฺฆ อยํ ฉนฺ-
นาโม ฉนฺนามสฺส อายสฺมโต อุปสมฺปทาเปกฺโข ฯ
สเจ สงฺฆ ฉนฺนามํ อุปสมฺปาเทติ ฉนฺนาเมน อุปชฺฌาเย-
น ฯ ยสฺสายสฺมโต ขมติ ฉนฺนามสฺส อุปสมฺปทา
ฉนฺนาเมน อุปชฺฌาเยน โส ตุณฺหสฺส ยสฺส ขมติ
โส กาเรยฺย ฯ อุปสมฺปนฺโน สงฺเฆน ฉนฺนาโม

នៅ(បើ)មិនគួរ ដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គ
នោះគប្បីពោលឡើង ។ ខ្ញុំពោលសេចក្តីនេះជាគំរប់ពីរដងផង ។ បពិត្រ
ព្រះគម្ពែរសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ (ដ្បិត) ឈ្មោះនេះជា
ឧបសម្បទាបេក្ខុរបស់លោកដ៏មានអាយុឈ្មោះនេះ ។ ឥទ្ធរសង្ឃញ៉ាំង
ឈ្មោះនេះឲ្យបានឧបសម្បទាដោយមានព្រះថេរៈឈ្មោះនេះជាឧបជ្ឈាយ៍។
ឯការញ៉ាំងឈ្មោះនេះឲ្យបានឧបសម្បទាដោយមានព្រះថេរៈឈ្មោះនេះ
ជាឧបជ្ឈាយ៍ (បើ) គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មាន
អាយុអង្គនោះគប្បីស្ងៀមនៅ (បើ) មិនគួរដល់លោកដ៏មានអាយុអង្គណា
លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង ។ ខ្ញុំពោលសេចក្តីនេះ
ជាគំរប់បីដងផង ។ បពិត្រព្រះគម្ពែរសង្ឃដ៏ចំរើន សូមព្រះសង្ឃ
ស្តាប់ខ្ញុំ (ដ្បិត) ឈ្មោះនេះជាឧបសម្បទាបេក្ខុរបស់លោកដ៏មានអាយុ
ឈ្មោះនេះ ។ ឥទ្ធរសង្ឃញ៉ាំងឈ្មោះនេះឲ្យបានឧបសម្បទាដោយ
មានព្រះថេរៈឈ្មោះនេះជាឧបជ្ឈាយ៍ ។ ឯការញ៉ាំងឈ្មោះនេះឲ្យបាន
ឧបសម្បទា ដោយមានព្រះថេរៈឈ្មោះនេះជាឧបជ្ឈាយ៍ (បើ) គួរ
ដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម
នៅ (បើ) មិនគួរ ដល់លោកដ៏មានអាយុអង្គណា លោកដ៏មាន
អាយុអង្គនោះគប្បីពោលឡើង ។ ឈ្មោះនេះដែលសង្ឃបានឲ្យឧបសម្បទា

สนฺตุฏฺฐายเน ฯเปฯ ปวิเวกายเน ฯ ๑ปติ สงฺฆสฺส ตสฺมา
ตุณฺหี ฯ ฯาเมตํ ภารยามีติ ฯ

[๘๖] เตน โข ปน สมเยน อญฺญตโร ภิกฺขุ
อุปสมฺปนฺนสมนนฺตรา อาจาริยํ อาปุจฺฉติ ฯ ภิกฺขู ฯา-
มาหิสุ มา อาวุโส ฯาวูปิ อกาลิ เนตํ กปฺป-
ติตี ฯ โส ฯามาหา เนวาหิ[1] อายสฺมนฺเต ยาจิ
อุปสมฺปาเนตุ มนฺติ ภิกฺขู มิ ตุมฺเห อยาจิตา อุป-
สมฺปาเนตุนฺติ ฯ ภควโต ฯตมตฺถํ อาโรเจสุ ฯ
น ภิกฺขเว อยาจิเตน อุปสมฺปาเนตพฺโพ โย อุป-
สมฺปาเนยฺย อาปตฺติ ทุกฺกฏสฺส ฯ อนุชานามิ ภิกฺขเว
ยาจิเตน อุปสมฺปาเนตุนฺ ฯ ฯาวญฺจ ปน ภิกฺขเว ยาจิ-
ตพฺโพ เตน อุปสมฺปนาเปกฺเขน สงฺฆ อุปสงฺกมิตฺวา
ฯกสึ อุตฺตราสงฺคิ กริตฺวา ภิกฺขูนิ ปาเท วนฺทิตฺวา

๑ ฉฏฺฐสฺสเร อุปสมฺปชฺชนฺติ ปฏฺฐปิ ปญฺจเก ทิสฺสติ ฯ

ដោយមានព្រះថេរៈឈ្មោះនេះជាឧបជ្ឈាយ៍ហើយ។ ការដែលឲ្យឧបសម្បទានេះ) គួរដល់ព្រះសង្ឃហើយ ព្រោះហេតុនោះបានជាសង្ឃស្ងៀមនៅ។ ខ្ញុំសូមចាំទុកសេចក្តីនេះដោយអាការស្ងៀមនៅយ៉ាងនេះឯង។

(๘๖) *សម័យនោះឯង មានភិក្ខុ ๑ រូបប្រព្រឹត្តអនាចារ គឺប្រព្រឹត្តល្មើស តាំងអំពីបានឧបសម្បទា។* ពួកភិក្ខុក៏បានពោលជាសង្ឃយ៉ាងនេះថា ម្នាលអាវុសោ អ្នកកុំធ្វើអំពើយ៉ាងនេះឡើយ អំពើនេះមិនគួរទេ។ ភិក្ខុនោះក៏ពោលយ៉ាងនេះវិញថា ខ្ញុំមិនបានឮឯលោកដ៏មានអាយុទាំងឡាយដោយពាក្យថា *សូមឲ្យអស់លោកឲ្យឧបសម្បទាដល់ខ្ញុំទេ* លោកទាំងឡាយខ្ញុំមិនបានអង្វរសោះ ហេតុអ្វីក៏ហ៊ានឲ្យឧបសម្បទាដល់ខ្ញុំ។ ភិក្ខុទាំងឡាយបានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលគេមិនបានសូម មិនត្រូវឲ្យឧបសម្បទា (គេ) ទេ (បើ) ភិក្ខុណាឲ្យឧបសម្បទាគេ ត្រូវអាបត្តិទុក្កដ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលមានគេសូម ទើបត្រូវឲ្យឧបសម្បទាគេបាន។ ម្នាលភិក្ខុទាំងឡាយ ឧបសម្បទាបេក្ខៈត្រូវសូមនឹងសង្ឃយ៉ាងនេះ គឺឧបសម្បទាបេក្ខៈនោះត្រូវចូលទៅកាន់ដំទុំសង្ឃ ហើយគប់ចីពរធ្វើស្មាម្ខាងរួចថ្វាយបង្គំ

ทุกฺกฏนฺติ อิมสฺมิญฺหิ อฏฺฐเม ปตฺตหตฺถา ปาทสฺส วชนียา สงฺฆํ ภนฺเต อุปสมฺปทํ ยาจามิ อุลฺลุมฺปตุ มํ ภนฺเต สงฺโฆ อนุกมฺปํ อุปาทายาติ ๆ ทุติยมฺปิ ยาจิตพฺพา ตติยมฺปิ ยาจิตพฺพา ๆ ฆฏิตฺวา ปกฺขา ปฏิพาหิตพฺพา สงฺโฆ ญาเปตพฺโพ ๆ สุณาตุ เม ภนฺเต สงฺโฆ อยํ ฐปฺปตฺตมาโล ฐปฺปตฺตมสฺส อายสฺมโต อุปสมฺปทาเปกฺโข ๆ ฐปฺปตฺตมาโล สงฺฆํ อุปสมฺปทํ ยาจติ ฐปฺปตฺตมาเลน อุปชฺฌายเตน ๆ ยทิ สงฺฆสฺส ปตฺตกลฺลํ สงฺโฆ ฐปฺปตฺตมาลํ อุปสมฺปาเทยฺย ฐปฺปตฺตมาเลน อุปชฺฌายเตน ๆ เอสา ญตฺติ ๆ สุณาตุ เม ภนฺเต สงฺโฆ อยํ ฐปฺปตฺตมาโล ฐปฺปตฺตมสฺส อายสฺมโต อุปสมฺปทาเปกฺโข ฐปฺปตฺตมาโล สงฺฆํ อุปสมฺปทํ ยาจติ ฐปฺปตฺตมาเลน อุปชฺฌายเตน ๆ สงฺโฆ ฐปฺปตฺตมาลํ อุปสมฺปาเทติ ฐปฺปตฺตมาเลน อุปชฺฌายเตน ๆ ยสฺสายสฺมโต ขมติ ฐปฺปตฺตมสฺส อุปสมฺปทา ฐปฺปตฺตมาเลน อุปชฺฌายเต

